**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal university of law and economics

# សារណាបញ្ចប់ការសិក្សា

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅ ព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា ឈន ដាវី**
**កញ្ញា នៅ រចនា**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ឡឿក ពិដោរ**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal university of law and economics

# សារណាបញ្ចប់ការសិក្សា

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា ឈន ដាវី**
**កញ្ញា នៅ រចនា**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ឡឹក ពិដោរ**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំទាំងពីរនាក់ ឈ្មោះ **កញ្ញា ឈន ដាវី** និង **កញ្ញា នៅ រចនា** ជានិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំទី៤ ឆមាសទី២ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤ សូមលំឱនកាយគោរពប្រណិប័តន៍ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ

-លោកឪពុក **ឈន ចំរើន** អ្នកម្តាយ **សឹង សុភាព**

-លោកឪពុក **នៅ សុខឿន** និងអ្នកម្តាយ **ម៉ៅ សាម៉ុន**

ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ អប់រំទូន្មាន ប្រៀនប្រដៅ និងការឧបត្ថម្ភទំនុកបម្រុងគ្រប់បែបយ៉ាង ទាំងធនធានថវិកា និងសម្ភារៈ ដើម្បីសិក្សា ពិសេសបានបណ្តុះនូវស្មារតី តស៊ូ អំណត់អត់ធ្មត់ ព្យាយាម ក្នុងការសិក្សារហូត ដល់កូនមានឱកាសបានបន្តការសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយលោកខិតខំ ពុះពារ មិនខ្លាចនឿយហត់ដើម្បីឱ្យកូនបានសិក្សា ខ្ពង់ខ្ពស់ដើម្បីឲ្យក្លាយជាទំពាំងស្នងឬស្សីដ៏ល្អសម្រាប់សង្គមជាតិ។

បន្ថែមពីនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ ដល់លោកគ្រូ អ្នកគ្រូ និងសាស្រ្តាចារ្យទាំងអស់ដែល បានខិតខំបង្ហាត់បង្រៀន ចំណេះដឹង ដោយមិនខ្លាចនឿយហត់ និងជួយផ្តល់ ឯកសារ ទិន្នន័យផ្សេងៗដើម្បីជំនួយស្មារតី ដែលជាការរួមចំណែកមួយយ៉ាងសំខាន់ដល់យើងខ្ញុំក្នុងការស្រាវជ្រាវ ដើម្បីសរសេរសារណាប្រកបដោយភាពជោគជ័យ សូមថ្លែងអំណរគុណចំពោះ

- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រងទាំងអស់ដែលបានសម្របសម្រួលរាល់តម្រូវការនៃការសិក្សារបស់និស្សិតគ្រប់ជំនាន់។

- លោកសាស្រ្តាចារ្យ **ឌឿក ពិដោរ** ជាសាស្រ្តាចារ្យណែនាំក្នុងដំណើរការនៃការសរសេរ សារណាដែលបានចំណាយពេលវេលាដ៏មានតម្លៃបង្ហាត់បង្ហាញ អប់រំ ណែនាំ ផ្តល់ឯកសារ និងត្រួតពិនិត្យ នូវរាល់ចំណុចខ្វះខាតព្រមទាំងកែលម្អយ៉ាងយកចិត្តទុកដាក់។

- ឯកឧត្តម **ប្រាជ្ញ ចន្ទ** ជាប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងថ្នាក់ដឹកនាំទាំងអស់គ្រប់លំដាប់ថ្នាក់ ដែលបានផ្តល់ឱកាសដល់យើងខ្ញុំបានស្រាវជ្រាវ និងស្វែងរកឯកសារដើម្បីទទួលបាននូវចំណេះដឹង ដែលជាកត្តាយ៉ាងសំខាន់ក្នុងការបញ្ចប់សារណានេះ ។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរគុណ និងសូមបួងសួងដល់ទេវតាឲ្យជួយប្រសិទ្ធពរជ័យសិរីមង្គលវិបុលសុខដល់សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសុខភាពល្អ ព្រមទាំងសម្រេចនូវគ្រប់ភារកិច្ច និងជួបតែសេចក្តីសុខចម្រើន ជានិច្ចនិរន្ត។

# អារម្ភកថា

រាប់ចាប់តាំងពីមានការបោះឆ្នោតឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់ឃើញមានសាលា ឬសកលវិទ្យាល័យណាមួយ ដែលលើកយកមុខវិជ្ជា ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ យកមកបង្រៀន ឬយកមកសិក្សាដោយឡែកអំពីចំណេះដឹងទាក់ទងនឹងការងារបោះឆ្នោតនៅឡើយទេ។

ទន្ទឹមនឹងនេះដែរ ក្រុមយើងខ្ញុំសង្កេតឃើញថា មានសៀវភៅមិនច្រើនឡើយ ដែលបានសរសេរ ឬចងក្រង និងបោះពុម្ពផ្សាយអំពីការងារបោះឆ្នោតសម្រាប់បម្រើការអាន និងការសិក្សាស្រាវជ្រាវ ក្រៅអំពី ច្បាប់ ស្ដីពី ការរៀបចំ និងប្រព្រឹត្តទៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង បទបញ្ជា និងនីតិវិធីសម្រាប់ ការបោះឆ្នោត សកល និង អសកល ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានចងក្រងឡើងនោះទេ ។ ដោយមូលហេតុខាងលើនេះ ក្រុមយើងខ្ញុំបានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលបានគ្រប់គ្រង ចាត់ចែង និងរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយឆ្លុះបញ្ចាំងជាមួយនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០២២ ដើម្បីបម្រើការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណា និងការអានរបស់សិស្សនិស្សិតក៏ដូចជាប្រិយមិត្តទូទៅ។ សារណានេះត្រូវបានរៀបរៀងនិងចងក្រងខ្លឹមសារសំខាន់ៗដូចជា៖

១. ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

២. ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

៣. ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត

៤. សេចក្ដីសន្និដ្ឋាន។

ក្រុមយើងខ្ញុំសង្ឃឹមថាសារណានេះនឹងក្លាយជាធាតុចូលមួយយ៉ាងសំខាន់សម្រាប់ជាជំនួយស្មារតី ដល់អ្នកសិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ ក្នុងការបង្កើនចំណេះដឹងទាក់ទងទៅនឹងជំនាញការងារបោះឆ្នោត សំដៅបានចូលរួមចំណែកតាមតួនាទីនិងភារកិច្ចរៀងៗខ្លួន ក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតនៅកម្ពុជា ដោយផ្អែកលើគោលការណ៍ ឯករាជ្យ អព្យាក្រឹត សច្ចៈ យុត្តិធម៌ តម្លាភាព ។ ខ្ញុំសូមអធ្យាស្រ័យ ចំពោះរាល់ចំណុចខ្វះខាត ក្នុងការសរសេរសារណានេះ ក្រុមយើងខ្ញុំ សូមរង់ចាំទទួលដោយសោមនស្សរីករាយ ចំពោះរាល់មតិកែលម្អដើម្បីស្ថាបនាពីសំណាក់សិស្សនិស្សិត សាស្ត្រចារ្យ បណ្ឌិតបញ្ញាវន្តទាំងអស់ និងសូមប្រសិទ្ធិពរបវរមហាប្រសើរកុំបីឃ្លាតឡើយ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................................................................................

១. លំនាំបញ្ហានៃការស្រាវជ្រាវ.................................................................................... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ................................................................................ ១

៣. គោលបំណងនៃការស្រាវជ្រាវ.................................................................................. ១

៤. វិសាលភាព និង ដែនកំណត់នៃការស្រាវជ្រាវ ...........................................................២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ...............................................................................២

៦. វិធីសាស្ត្រស្រាវជ្រាវ....................................................................................................៣

៧. រចនាសម្ពន្ធ័នៃការសិក្សាស្រាវជ្រាវ .........................................................................៣

**ជំពូកទី១**

**ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់**

**ផ្នែកទី១. បទប្បញ្ញត្តិទូទៅ និង សមត្ថកិច្ចគ្រប់គ្រង**.............................................................៤

១.១. សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គ.ជ.ប .......................................៤

១. ២. សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប........................................៨

១. ៣. លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ..................................................៨

១. ៤. ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត ............ ៩

**ផ្នែកទី២. សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គឃ.សប** ..................៨

២.១ លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គឃ.ស.ប..................................................៨

២.២ បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំង........................ ៩

**ផ្នែកទី៣. ប្រព័ន្ធនៃការបោះឆ្នោត និងការបែងចែកអាសនៈ....................................១១**

៣.១. ប្រព័ន្ធនៃការបោះឆ្នោត .................................................................................. ១១

៣.២. ការបែងចែកអាសនៈ ...................................................................................... ១១

## ជំពូកទី២

## ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់

**ផ្នែកទី១. ការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់..........................................................................១៤**

១.១. ភាពមានមានសិទ្ធិឈរឈ្មោះជាបេក្ខជន ..................................................................... ១៤

១.២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន .......................................................................... ១៤

១.៣. ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ.សប..........................................................១៧

១.៤. ការពិនិត្យ និងសម្រេចរបស់ គឃ.សប លើពាក្យសុំចុះបញ្ជីបេក្ខជន ................................ ១៨

១.៥. ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត...........................................................................................................២០

**ផ្នែកទី២. ការឃោសនាបោះឆ្នោត ..........................................................................២២**

២.១. បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត....................................................................២២

២.២. សម្ភារអប់រំអ្នកបោះឆ្នោត.......................................................................................៣២

២.៣. រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ ...................................................................៣៤

២.៤. ភារកិច្ច និងកាតព្វកិច្ច របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ..................................................៣៥

## ជំពូកទី៣

## ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត

**ផ្នែកទី១. ការបោះឆ្នោត ...................................................................................... ៣៦**

១.១. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ..................................................៣៦

១.២. ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឧបករណ៍ចាំបាច់សម្រាប់ការបោះឆ្នោត........................៣៦

១.៣. ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ. ......................................................................៣៨

១.៤. ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត........... ៤១

១.៥. ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត...... ៤៥

**ផ្នែកទី២. ការរាប់សន្លឹកឆ្នោត**......................................................................................................**៤៥**

២.១. ការបិទការបោះឆ្នោត.............................................................................................................. ៤៥

២.២. ការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត........................................................................ ៤៨

២.៣. សន្លឹកឆ្នោតបានការ និង សន្លឹកឆ្នោតមិនបានការ ...................................................................... ៤៩

**ផ្នែកទី៣. ការប្រកាសលទ្ធផលបោះឆ្នោត**......................................................................................**៥១**

**៣.១. លទ្ធផលបណ្តោះអាសន្ន**........................................................................................................**៥១**

៣.១.១. កិច្ចប្រតិបត្តិការរបស់ គឃ.សប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត....................................................................................................................... ៥១

៣.១.២. ការពិនិត្យ និងចុះហត្ថលេខាលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់ ...........................................................................................................................៥៣

៣.១.៣. ការបង្កើតមជ្ឈមណ្ឌលនៃ គធ.ខប. សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់............................................................................................................. ៥៥

**៣.២. លទ្ធផលផ្លូវការ** .......................................................................................................................**៥៦**

៣.២.១. ការរៀបចំ និងផ្សព្វផ្សាយសេចក្តីប្រកាសលទ្ធផលផ្លូវកាវនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ .........................................................................................................................៥៧

**សេចក្តីសន្និដ្ឋាន**...........................................................................................................**៥៨**

**អនុសាសន៍**..............................................................................................................**៥៩**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | |
|---|---|
| ១. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត | គ.ស.អ |
| ៣. គណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៤. លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៥. ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៦. គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| ៧. គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៨. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៩. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| ១០. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ១១. បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ប.ន.ឃ.ស |
| ១២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១៣. ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| ១៤. ទម្រង់បែបបទលេខ | ទ. |

## ទម្រង់បែបបទលេខ (ទ.)


១. (ទ. ១០០២) : កិច្ចសន្យាបម្រើការងារក្នុងគណៈកម្មាការការិយាល័យបោះឆ្នោត។

២. (ទ. ១០០៨) : ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប។

៣. (ទ. ១១០១) : ទិន្នន័យកំណត់ហេតុនៃការបោះឆ្នោត។

៤. (ទ. ១១០២) : ទិន្នន័យកំណត់ហេតុការរាប់សន្លឹកឆ្នោត។

៥. (ទ.១១០៣) : កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

៦. (ទ.១១០៧) : លិខិតបញ្ជូន និងប្រគល់ ទទួលឯកសារបោះឆ្នោត។

៧. (ទ.១១០៨) : តារាងកំណត់សំឡេងឆ្នោត។

៨. (ទ.១១០៩) : តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

៩. (ទ.១១១០) : តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតឃុំ សង្កាត់ក្នុងរាជធានី ខេត្ត។

១០. (ទ.១១១១) : តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

១១. (ទ. ១១១២) : តារាងត្រួតពិនិត្យសម្ភារៈ។

១២. (ទ. ១១១៣) : កំណត់ហេតុវាយតម្លៃគណៈកម្មាការការិយាល័យបោះឆ្នោត។

១៣. (ទ. ១១១៥) : បញ្ជីវត្តមានគណបក្សនយោបាយ និងអ្នកសង្កេតពេលរាប់សន្លឹកឆ្នោត។

១៤. (ទ.១១១៨) : លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

១៥. (ទ. ១១២០) : បញ្ជីវត្តមានអ្នកសង្កេតការនៅពេលបោះឆ្នោត។

១៦. (ទ. ១១២១) : ការកំណត់លំដាប់លេខរៀងបញ្ជីបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។

១៧. (ទ. ១២០២) : ពាក្យបណ្តឹង។

១៨. (ទ. ១២០៣) : សម្រង់សេចក្តីសម្រេច។

១៩. (ទ.១១០៥ធខ) :ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំសង្កាត់ផ្ទៀងផ្ទាត់ដោយរាជធានី ខេត្ត។

២០. (ទ.១១១៦ពត): តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

អនុវត្តកិច្ចព្រមព្រៀងសន្តិភាពនៃសន្និសីទអន្តរជាតិស្តីពីកម្ពុជា នៅទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ការបោះឆ្នោតជ្រើសតាំងសភាធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានរៀបចំដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា (United Nations Transitional Authority in Cambodia"UNTAC")។ ទន្ទឹមគ្នានឹងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញបានប្រែក្លាយទៅជារដ្ឋសភានៃកម្ពុជា។ ស្ថិតក្នុងនីតិកាលទី១ នៃរដ្ឋសភា នៅឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមចង់ឱ្យមានការគ្រប់គ្រង និងរៀបចំការបោះឆ្នោតដោយកម្ពុជាខ្លួនឯង ដែលពេលនោះបានប្រគល់ភារកិច្ចឱ្យក្រសួងមហាផ្ទៃបង្កើតការិយាល័យកណ្តាលបោះឆ្នោត ដើម្បីសិក្សាស្រាវជ្រាវ និងតាក់តែងគម្រោងការរៀបចំការបោះឆ្នោត។ ការផ្តួចផ្តើមនេះកាន់តែបានបង្ហាញឱ្យឃើញច្បាស់ចាប់ពីខែឧសភា ឆ្នាំ១៩៩៧ នៅពេលដែលរាជរដ្ឋាភិបាលបានប្រកាសកំណត់ការបោះឆ្នោតសកលនៅឆ្នាំ១៩៩៨។ ជាពិសេសក្របខណ្ឌច្បាប់ត្រូវបានបំពេញគ្រប់គ្រាន់បន្ទាប់ពីរដ្ឋសភាបានអនុម័តច្បាប់ស្តីពីសញ្ជាតិ ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ។ នៅលើកដំបូងបង្អស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានគ្រប់គ្រងនិងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ២ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨។ ហើយជាបន្តបន្ទាប់ គ.ជ.ប បានគ្រប់គ្រងនិងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨។ ដោយឡែក ដោយផ្អែកលើសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដែលបានប្រគល់ឱ្យដោយច្បាប់នានាជាធរមាននាពេលនោះ គ.ជ.ប បានបន្តគ្រប់គ្រង និងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ដែលប្រព្រឹត្តទៅនៅថ្ងៃទី០៣ខែកុម្ភៈ ឆ្នាំ២០០២, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧, ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧, និងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង បទបញ្ញានីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អណ្តត្តិទី៥ មានលក្ខណៈពិសេសដូចម្តេចខ្លះ? តើការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ គឺមានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងថ្មីមួយទៀត សម្រាប់ជា ជំនួយដល់សិស្សនិស្សិតជំនាន់ក្រោយ និងបុគ្គលដែលមានបំណងចង់ស្វែងយល់ពីចំណេះដឹងទូទៅ ពាក់ព័ន្ធការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងចង់បង្ហាញពីដំណើរការនៃការបោះឆ្នោតជាពិសេស នៅអាណិត្តទី៥។ គោលបំណង ចម្បងដែលជំរុញដល់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះគឺៈ

ក. ដើម្បីស្វែងយល់លម្អិតអំពីការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ។

ខ. ដើម្បីស្វែងយល់អំពីដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

គ. ដើម្បីស្វែងយល់លម្អិតអំពី ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រកាសលទ្ធផល ។

## ៤. វិសាលភាព និង ដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះ យើងខ្ញុំបានផ្តោតសំខាន់ទៅលើការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ នៅព្រះរាជាណាចក្រកម្ពុជាអណត្តិទី៥ ដែលបានប្រព្រឹត្តទៅកាលពី ថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ ជាគោល ។ ការសិក្សាស្រាវជ្រាវនេះដោយផ្អែកលើឯកសារក្នុងប្រព័ន្ធអ៊ីនធើណេត និងប្រមូលឯកសារបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធទៅនឹងប្រធានបទ ពិសេសយកមកពីក្នុងបណ្ណាល័យរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចុះផ្ទាល់ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៤។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

❖ សម្រាប់រាជរដ្ឋាភិបាល

បានគោរពតាម រដ្ឋធម្មនុញ្ញដែលបានកំណត់ថា ត្រូវប្រកាន់យកនូវរបបនយោបាយលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ដូចមានចែងក្នុងមាត្រា ៥១.-ថ្មី ក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរី ពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី ។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

❖ ឆ្លុះបញ្ចាំងពីការប្រែប្រួលនៃការគ្រប់គ្រងសម្រាប់ការបោះឆ្នោត

ផ្តល់គំនិតថ្មីៗដល់ក្រសួង-ស្ថាប័ននានា ដែលពាក់ពន្ធ័នឹងស្ថាប័នបោះឆ្នោត ក្នុងការកែលំអរនូវចំនុចខ្វះខាតខ្លះៗឱ្យអនុវត្តកាន់តែប្រសើរឡើង។

❖ ចំពោះសមាជិកក្រុមស្រាវជ្រាវ

- អាចបង្កើននូវចំនេះដឹង និង បទពិសោធន៍

- បង្កើននូវសាមគ្គីភាព និង កិច្ចសហការគ្នាយ៉ាងល្អរវាងសមាជិកក្រុម
- បង្កើនសមត្ថភាពកាន់តែប្រសើរក្នុងការវិភាគ និង ការស្វែងរកពត៌មាន

❖ **ចំពោះសិស្សនិស្សិត និង អ្នកអានទូទៅ**

បង្កើនការយល់ដឹងបន្ថែមពីការវិវត្តន៍នៃការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់បន្ថែមទៀត ។ ពិសេស សម្រាប់ជាទឡ្ហីករណ៍ និង ចក្ខុវិស័យ ក្នុងការសិក្សាស្រាវជ្រាវក្រោយៗបន្តទៀត ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការជ្រើសរើសប្រធានបទនេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ក្រុមយើងខ្ញុំ មានវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗអាស្រ័យទៅតាមបទពិសោធន៍ដែលធ្លាប់បានសិក្សា លទ្ធភាព និងសមត្ថភាព ដែលមានរៀងៗខ្លួន មកបញ្ចូលគ្នាក្នុងការសរសេរសារណានេះឱ្យបានជោគជ័យ ដើម្បីសម្រេចគោលបំណងរួមតែមួយ។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ លើប្រធានបទនេះ ដោយ ការប្រមូលទិន្នន័យនិងឯកសារតាមរយៈឯកសារពាក់ព័ន្ធពីបណ្ណាល័យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងប្រព័ន្ធអ៊ីនធើណេត។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ប្រធានបទដែលយើងធ្វើការសិក្សាស្រាវជ្រាវនេះចែកចេញជា ៣ ជំពូកដូចខាងក្រោមគឺៈ

សេចក្តីផ្តើម ៖ បង្ហាញពីលំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ, ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ, គោលបំណងនៃការសិក្សាស្រាវជ្រាវ, ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ, សារៈសំខាន់នៃ ការសិក្សាស្រាវជ្រាវ , វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃសារណា។

ជំពូកទី១ ៖ បង្ហាញពីការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួមមានៈ បទប្បញ្ញត្តិទូទៅ និងសមត្ថកិច្ចគ្រប់គ្រង, សមាសភាព រចនាសម្ព័ន្ធនិងរបៀបរបបធ្វើការងាររបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងប្រព័ន្ធនៃការបោះឆ្នោត និងការបែងចែកអាសនៈ។

ជំពូកទី២ ៖ ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់ រួមមានៈ ការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនិងបញ្ជីបេក្ខជនឈរឈ្មោះជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់, ការឃោសនាបោះឆ្នោត។

ជំពូកទី៣ ៖ ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ៈ ចំណុចចុងក្រោយគឺធ្វើការសង្ខេបទៅលើគ្រប់ចំណុចដែលបានសិក្សាស្រាវជ្រាវ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវព្រមទាំងមតិយោបល់មួយចំនួន។

# ជំពូកទី១

# ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់

# ជំពូកទី១

# ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់

## ផ្នែកទី១. បទប្បញ្ញត្តិទូទៅ និង សម្ថកិច្ចគ្រប់គ្រង

### ១.១. សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គ.ជ.ប

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានឈ្មោះជាអក្សរកាត់ (គ.ជ.ប) ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មការឃុំសង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីអនុវត្តការងាររបស់ខ្លួន[១] ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដោយឯករាជ្យ និង អព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ។ សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិក នៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរ អព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត[២] ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ០៩ (ប្រាំបួន) រូប និង បុព្វសិទ្ធិដែលកំណត់ក្នុងច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈនិងបុព្វសិទ្ធិស្មើរបស់ ដែលរួមមាន ៖

- ប្រធាន ០១ (មួយ) រូប មានឋានៈនិងបុព្វសិទ្ធិស្មើ ឧបនាយករដ្ឋមន្ត្រី
- អនុប្រធាន ០១ (មួយ) រូប មានឋានៈនិងបុព្វសិទ្ធិស្មើ ទេសរដ្ឋមន្ត្រី
- សមាជិក ០៧ (ប្រាំពីរ) រូប មានឋានៈនិងបុព្វសិទ្ធិស្មើ រដ្ឋមន្ត្រី

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរទាំងពីរភេទ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ក្នុងពេលបំពេញការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- មានអាយុយ៉ាងតិច ៣៥ (សាមសិបប្រាំ) ឆ្នាំ គិតដល់ថ្ងៃតែងតាំង
- មានសិទ្ធិបោះឆ្នោត
- មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ
- មានបទពិសោធន៍ការងារយ៉ាងតិច ១០ (ដប់) ឆ្នាំ

---

[១]មាត្រា ២ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

[២]មាត្រា ៣ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

- មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត[៣] ។

**សមាសភាពទាំង ០៩ (ប្រាំបួន) រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសដោយ៖**

- ០៤ (បួន) រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល
- ០៤ (បួន) រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល
- ០១ (មួយ) រូបទៀត ជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវធ្វើការសម្របសម្រួលជាមួយគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីប្រកាសជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសាធារណៈ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ ។ បន្ទាប់មក គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវសម្របសម្រួលជាមួយគណបក្សទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីពិនិត្យជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពីក្នុងចំណោមបេក្ខជនដែលបានដាក់ពាក្យស្នើសុំ ដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

បែបបទ និងនីតិវិធីនៃការជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ផ្អែកលើសមាសភាពដែលបានជ្រើសរើសខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវរៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីរដ្ឋសភាថ្មីចូលកាន់តំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង[៤] ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអាណត្តិ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលសមាសភាពថ្មីចូលកាន់តំណែង ។

[៣] មាត្រា ៥ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

[៤] មាត្រា ៦ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ច ដើម្បីចាត់ចែងរៀបចំបោះឆ្នោតស្របតាមច្បាប់ជាធរមាន[៥] ។

មុខងារជាប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈនិងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន រហូតដល់ថ្ងៃបញ្ចប់មុខតំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយ ត្រូវសុំលាលែងពីគណបក្សនយោបាយ ហើយអាចចូលជាសមាជិកគណបក្សនយោបាយវិញបានក្នុងរយៈពេលយ៉ាងតិច០២ (ពីរ) ឆ្នាំ បន្ទាប់ពីបញ្ចប់អាណត្តិការងារ ឬបាត់បង់តំណែង ឬ ត្រូវបានបណ្តេញចេញដូចមានចែងក្នុងមាត្រា ៧ មាត្រា ៩ និងមាត្រា ១០ នៃច្បាប់នេះ ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិកឬ/និងជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគមន៍ សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្មឬ/និងមន្ត្រីរាជការ ត្រូវសុំលាលែងពីអង្គការមិនមែនរដ្ឋាភិបាល សមាគមន៍ សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ[៦] ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម៖

- សាមីខ្លួន ទទួលមរណភាព
- សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ
- សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ[៧] ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានគណនេយ្យភាពចំពោះមុខរដ្ឋសភា ។

ការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការ

[៥] មាត្រា ៧ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

[៦] មាត្រា ៨ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

[៧] មាត្រា ៩ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

បោះឆ្នោតជាសមត្ថកិច្ចរបស់រដ្ឋសភា[៨] ។

ក្នុងករណីដែលមានប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់ពីមុខតំណែង គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវសម្របសម្រួលជាមួយគណបក្សនយោបាយពាក់ព័ន្ធ ដើម្បីប្រកាសជ្រើសរើសជាសាធារណៈនូវបេក្ខភាពបេក្ខជនដែលត្រូវជំនួសមុខតំណែងដែលទំនេរ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ ។

បន្ទាប់មក គណបក្សពាក់ព័ន្ធត្រូវជ្រើសរើសសមាសភាពថ្មីពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ដាក់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំដាក់សមាសភាពថ្មីនេះ ជូនរដ្ឋសភាបោះឆ្នោតទុកចិត្ត តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋាភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងនិងយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ ក្នុងករណី ដែលគ្មានការរៀបចំបោះឆ្នោត។

ករណីគណបក្សនយោបាយពាក់ព័ន្ធខកខានមិនបានជ្រើសរើសសមាសភាពថ្មីតាមការកំណត់ខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវធ្វើការជ្រើសរើសបេក្ខភាពបេក្ខជន ដែលត្រូវជំនួសមុខតំណែងទំនេរនោះដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាពក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ថ្ងៃ ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ថ្ងៃក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ ០៣ (បី) ថ្ងៃក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។

បែបបទ នីតិវិធីនៃការដាក់ពាក្យ ការជ្រើសរើស និងការរៀបចំបញ្ជីបេក្ខជនដាក់ជូនរដ្ឋសភាត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានទទួលការតែងតាំងជំនួសកន្លែងទំនេរនោះ ត្រូវធ្វើសច្ចាប្រណិធានចូលកាន់តំណែងភ្លាម ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរនោះ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត[៩] ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តន៍តួនាទីរបស់ខ្លួនដោយមិនលម្អៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ការគំរាមកំហែង ការបំភិតបំភ័យ ឬការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីបុគ្គល ឬស្ថាប័នណាមួយឡើយ ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបានការធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ក្នុងករណីចាំបាច់ តាមសំណូមពររបស់សាមីខ្លួន ។

---

[៨] មាត្រា ១០ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

[៩] មាត្រា ១១ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខ័ណ្ឌសមត្ថកិច្ចនិងមុខងាររបស់ខ្លួនឡើយ[១០] ។

### ១. ២. សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលបង្កើតដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោត ។ សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុង របស់ គ.ជ.ប ។

### ១.៣. លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប

បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ត្រូវអនុវត្តតាម មាត្រា ១៦ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។ សមាសភាព គធ.ខប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និង មន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាលរងស្រុករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវតុលាការផ្តន្ទាទោស ដាក់ពន្ធនាគាពីបទឧក្រិដ្ឋ ឬបទបមជ្ឈិម ហើយមិនទាន់មាននីតិសម្បទាឡើងវិញ។

សមាសភាព គធ.ខប ត្រូវបានជ្រើសរើសដោយអនុលោមតាមប្រព័ន្ធជ្រើសរើសនិង គណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

សមាសភាព គធ.ខប ដែលត្រូវបានតែងតាំង ត្រូវធ្វើសច្ចាប្រណិធានមុន ចាប់ផ្តើមចូលបម្រើការងារ ។

### ១.៤. ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត

យោងតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប អាចចេញសេចក្តីសម្រេច ប្រគល់សិទ្ធិរបស់ខ្លួនដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) គណៈកម្មការ ឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) ឬមន្ត្រី ឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត ។

## ផ្នែកទី២. សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គឃ.សប

### ២.១. លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

[១០] មាត្រា ៨ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

សមាសភាព គណៈកម្មាធិការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និង មន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជន ឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ហើយមិនទាន់មាននីតិសម្បទាឡើងវិញ[១១]។

## ២.២. បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំង

បែបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គ.ក.ប ត្រូវអនុវត្តតាមមាត្រា ៣៥ នៃ ច.គ.ជ.ប និងបទបញ្ញាផ្ទៃក្នុងរបស់ គ.ជ.ប[១២]។

សមាសភាព គ.ក.ប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរៈភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរង ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ[១៣]។

អ្នកដែលត្រូវបានជ្រើសរើសជាសមាជិក គ.ក.ប គឺជាបេក្ខជនដាក់ពាក្យសុំចូលបម្រើការងារណាដែលបានទទួលជោគជ័យក្នុងការជ្រើសរើស បានចូលរួម ក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង និងបានចុះហត្ថលេខាលើកិច្ចសន្យាបម្រើ ការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២) នៅក្រោយពេលវគ្គបណ្តុះបណ្តាល ត្រូវបានបញ្ចប់ ។ ក្នុងការជ្រើសរើសនេះ ត្រូវ ផ្តល់អាទិភាពចំពោះបេក្ខជនដែលធ្លាប់មានបទពិសោធន៍ការងារបោះឆ្នោតពីមុនមក ឬបទពិសោធន៍ការងារពាក់ព័ន្ធនឹងមុខតំណែង ។

បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួម វគ្គបណ្តុះបណ្តាល ត្រូវដាក់ជំនួសជាបន្ទាន់ដោយបេក្ខជន បម្រុង ។

ប្រសិនបើគ្មានបេក្ខជនបម្រុងសម្រាប់ជំនួស គឃ.សប ត្រូវ ចាត់ចែងស្នើសុំ គ.ជ.ប តាមរយៈ គធ.ខប ជ្រើសរើសអ្នកជំនួស ជាបន្ទាន់ ។

[១១] មាត្រា ២៧ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

[១២] មាត្រា ៣៥ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

[១៣] បទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ២.១១ ទំព័រ ៨

- ➢ ដើម្បីទទួលបានការជ្រើសរើស និងបានបម្រើការងារក្នុងលក្ខណៈជាប់កិច្ចសន្យា ជាសមាជិក គ.ក.ប បេក្ខជនដាក់ពាក្យសុំបម្រើការងារត្រូវ ៖

- ឆ្លងកាត់ដោយជោគជ័យនូវការជ្រើសរើស ដែលគ្រប់គ្រង ពិនិត្យដោយអនុគណៈកម្មការជ្រើសរើស ។
- គោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាម ច.ប.ឃ.ស ព្រមទាំងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។
- យល់ព្រមធ្វើសច្ចាប្រណិធានថា ប្រកាន់ជំហរអព្យាក្រឹត និងមិនលម្អៀង ។
- យល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កម្រៃ ។
- បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលពេញម៉ោង ។
- ចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបម្រើការងារក្នុងគណៈ កម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២)[១៤]។
- កិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត(ទ.១០០២) សម្រាប់បំពេញកិច្ចសន្យាបម្រើការងារក្នុង គ ក ប ត្រូវបញ្ជាក់ព័ត៌មានអ្នកដែលត្រូវតែងតាំង ដូចខាងក្រោម៖
    - ឈ្មោះអាសយដ្ឋាន និងភស្តុតាងបញ្ជាក់ពីភាពមានសិទ្ធិបោះឆ្នោត មុខតំណែងក្នុង គ.ក.ប ។
    - លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ។
    - លក្ខខណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវ ។
    - ការសន្យាយល់ព្រមទទួលយកភារកិច្ច លក្ខខណ្ឌការងារ និង ប្រាក់កម្រៃ ។
    - ការសន្យាថានឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និង មិនលម្អៀង ។
    - ការសន្យាថានឹងអនុវត្តតាម ច.ប.ឃ.ស បទបញ្ជា និងនីតិវិធី ព្រមទាំងរាល់សេចក្ដីណែនាំរបស់ គ.ជ.ប ។បោះឆ្នោត និងការសន្យាថានឹងគោរពតាមគោលការណ៍នៃការបោះឆ្នោត ។ហត្ថលេខារបស់សាមីខ្លួន និងហត្ថលេខារបស់ប្រធាន គឃ.សប ។
    - សមាសភាព គ.ក.ប ត្រូវតែជ្រើសរើស ដោយផ្អែកតាមប្រព័ន្ធជ្រើសរើស និង គណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គ.ជ.ប។

- គឃ.ខប ត្រូវប្រគល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងជាសមាជិក គ.ក.ប ទាំងអស់តាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្តរបស់ខ្លួន ដោយភ្ជាប់ជាមួយ នូវកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោត (ទ.១០០២) ដែលបានបំពេញ និងចុះហត្ថលេខារួចម្នាក់ៗ ១ (មួយ) ច្បាប់ ដើម្បីស្នើសុំសេចក្ដីសម្រេចតែងតាំងពី គ.ជ.ប ។
- នៅពេលទទួលបានសំណើតែងតាំង គ.ជ.ប ត្រូវពិនិត្យ និងចេញសេចក្ដីសម្រេចតែងតាំង គ.ក.ប ហើយត្រូវរក្សាទុកឯកសារនៃបញ្ជីឈ្មោះមន្ត្រីការិយាល័យបោះឆ្នោតទាំងនោះជាផ្លូវការ[១៥] ។

---

[១៤] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ២.១១ ទំព័រ ៩

[១៥] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ២.១១ ទំព័រ ១០

- បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ គ.ជ.ប គធ.ខប ត្រូវបញ្ជូនបន្ត និង ណែនាំ គឃ.សប ឱ្យបំពេញប័ណ្ណសម្គាល់ខ្លួន និងផ្តល់ជូនសមាជិក គ.ក.ប សម្រាប់ពាក់នៅពេលបំពេញភារកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន ។
- សមាជិក គ.ក.ប ត្រូវស្ថិតនៅក្នុងមុខតំណែងរហូតដល់ថ្ងៃប្រកាសលទ្ធផល បណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងការិយាល័យរបស់ខ្លួន និងក្រោយពី បានប្រគល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃ ការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតចប់សព្វ គ្រប់ជូន គឃ.សប ។ ផ្អែកតាមមុខតំណែងរបស់ខ្លួន សមាជិក គ.ក.ប ម្នាក់ៗ នឹងទទួលបានប្រាក់កម្រៃជាប្រាក់រៀលសម្រាប់ការងាររបស់ខ្លួន ដោយគិត កាលបញ្ចូលទាំងថ្លៃម្ហូបអាហារ និងថ្លៃធ្វើដំណើរផង ។
- ចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់ជាកម្រៃ សម្រាប់ការបំពេញ ការងារនៃសមាជិក គ.ក.ប ក្នុងរយៈពេល ៤ (បួន) ថ្ងៃ ដោយ គិតទាំងការចូលរួមវគ្គបណ្តុះបណ្តាលផង ។
- ក្នុងករណីសមាជិក គ.ក.ប ណាដែលតម្រូវឱ្យស្ថិតក្នុង មុខតំណែងយូរជាងការកំណត់ មន្ត្រីនោះនឹងត្រូវទទួលបានប្រាក់កម្រៃបន្ថែមតាម សេចក្តីសម្រេចរបស់ គ.ជ.ប។

- គឃ.សប ត្រូវអនុវត្តការវាយតម្លៃសមាជិក គ.ក.ប ទាំងអស់ចំណុះឃុំ សង្កាត់ រយៈពេល ២ (ពីរ) សប្តាហ៍យ៉ាងយូរ បន្ទាប់ពីថ្ងៃបោះឆ្នោត ។
    - នៅមុនបញ្ចប់ភារកិច្ចរបស់ខ្លួន គឃ.សប ត្រូវផ្តល់កំណត់ហេតុ វាយតម្លៃសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោត (ទ.១១១៣) ដែលបានបំពេញរួចហើយទៅ គធ.ខប ។
    - គធ.ខប ត្រូវធ្វើកំណត់ហេតុវាយតម្លៃសមាជិកគណៈកម្មការ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១១៣) ទាំងអស់ ចំណុះរាជធានី ខេត្តម្នាក់ៗ ១ (មួយ) ច្បាប់ជន គ.ជ.ប ។
    - គ.ជ.ប ត្រូវកត់ត្រាបន្ថែមទិន្នន័យនៃកំណត់ហេតុវាយតម្លៃសមាជិក គ.ក.ប ទាំងអស់ទៅក្នុងបញ្ជីឈ្មោះនៃសមាជិក គ.ក.ប ដែលត្រូវរក្សាទុក[១៦] ។

## ផ្នែកទី៣. ប្រព័ន្ធនៃការបោះឆ្នោត និងការបែងចែកអាសនៈ

### ៣.១. ប្រព័ន្ធនៃការបោះឆ្នោត

- ការបោះឆ្នោតជ្រើសរើស កបឃ.ស ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ដោយយកឃុំ សង្កាត់ ជាមណ្ឌលបោះឆ្នោត និងបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ។
- ចំនួនអាសនៈនៃ កបឃ.ស ត្រូវស្មើគ្នានឹងចំនួនសមាជិក កបឃ.ស ដែលកំណត់ដោយ អនុក្រឹត្យអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- សមាជិក កបឃ.ស ត្រូវជ្រើសរើសចេញពីក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយដែល បានជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់ [១៧]។

### ៣.២. ការបែងចែកអាសនៈ

[១៦] បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ២.១១ ទំព័រ ១១

[១៧] បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៤.១-៤.៣ ទំព័រ ២៧

- គជ.ឧប ត្រូវធ្វើការបែងចែកអាសនៈ កបឃ.ស ។
- អាសនៈនៅក្នុង កបឃ.ស ត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការ បោះឆ្នោតក្នុង ឃុំ សង្កាត់នីមួយៗ ។
- ដើម្បីបែងចែកអាសនៈ កបឃ.ស នីមួយៗ ត្រូវអនុវត្តតាមករណី ដូចតទៅ៖

- ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះ បោះឆ្នោតតែមួយគត់ ឃុំ សង្កាត់នោះក៏ត្រូវធ្វើការបោះឆ្នោតដែរ ។
- ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបឃ.ស ក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយឈរឈ្មោះ និង មណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយ តែមួយជាប់ឆ្នោត ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ តែមួយនោះ ដូចគ្នាតាមលំដាប់លេខរៀងពីលើមកក្រោម រហូតដល់គ្រប់អាសនៈ នៅក្នុងក្រុមប្រឹក្សា។
- ក្នុងករណីការបោះឆ្នោតក្នុងឃុំ សង្កាត់ មានបញ្ជីបេក្ខជននៃគណបក្សនយោបាយ លើសពីមួយជាប់ឆ្នោត អាសនៈនៅក្នុង កបឃ.ស នោះ ត្រូវបែងចែកដោយ ផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោត តាមជំហានទាំងឡាយ ដូចខាងក្រោម ៖

**ជំហានទី១៖ ការកំណត់កូតា (Quota)**

- កូតា គឺជាចំនួនសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗដែលកំណត់ឡើងសម្រាប់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ទទួលបាន ១ (មួយ) អាសនៈ ។
- ដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុប របស់មណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗចែកនឹងចំនួនអាសនៈសរុប ដែលបានកំណត់សម្រាប់ក្រុមប្រឹក្សានៃឃុំ សង្កាត់ នីមួយៗនោះតាមរូបមន្តដូចខាងក្រោម ៖

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ៖

- $\text{ក}_{\text{ត}}$ តាងឱ្យកូតា ដែលជាផលចែកមិនគិតសំណល់ចែក។
- $\text{ស}_{\text{ស}}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ។
- $\text{អ}_{\text{ស}}$ តាងឱ្យចំនួនអាសនៈសរុប ។

**ជំហានទី២៖ ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈ លើកទី១**

- ដើម្បីកំណត់ចំនួនអាសនៈបឋម សម្រាប់ផ្តល់ឱ្យទៅបញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗ ត្រូវយកចំនួនសន្លឹកឆ្នោតបានការ សរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ មកចែកនឹងកូតា តាមរូបមន្ត ដូចខាងក្រោម៖

$$\text{អ}_{\text{ទ}} = \frac{\text{សំ}_{\text{ប}}}{\text{កិ}_{\text{ត}}}$$

- o បន្ទាប់ពីគណនាតាមរូបមន្តជំហានទី២ គ្រប់បញ្ជីបេក្ខជននៃ គណបក្សនយោបាយទាំងអស់រួច មក ហើយប្រសិនបើគ្មាន អាសនៈនៅសល់នោះចំនួនអាសនៈត្រូវកំណត់យកតែម្តង ។

**ជំហានទី៣៖ ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈ លើកទី២**

ក្នុងករណីមានអាសនៈនៅសល់ បន្ទាប់ពីការបែងចែកអាសនៈ លើកទី១ គជ.ខប ត្រូវបន្តបែងចែក អាសនៈដែលនៅសល់នោះ ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដោយកំណត់ យកមធ្យមភាគ ខ្ពស់បំផុតតាមការគណនា ដូចខាងក្រោម ៖

- o មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្ស នយោបាយនីមួយៗ ត្រូវបានកំណត់ដោយ យក ចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជី បេក្ខជននៃគណបក្សនយោបាយនីមួយៗ ចែកនឹង ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្ស នយោបាយនីមួយៗបានទទួលក្នុងការបែងចែក លើកទី១ បូកនឹងលេខនិមិត្តចំនួន ១ (មួយ) តាមរូបមន្ត ដូចខាងក្រោម៖

$$\text{ម}_{\text{ធ}} = \frac{\text{សំ}_{\text{ប}}}{\text{អ}_{\text{ទ}}+១}$$

ក្នុងនោះ ៖

- $\text{ម}_{\text{ធ}}$ តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្ស នយោបាយនីមួយៗ ។
- $\text{ស}_{\text{ច}}$ តាងឱ្យសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃ គណបក្សនយោបាយនីមួយៗ ។
- $\text{អ}_{\text{ទ}}$ តាងឱ្យចំនួនអាសនៈបឋមដែលបញ្ជីបេក្ខជននៃ គណបក្សនយោបាយនីមួយៗទទួលបាន ។
- ១ ជាលេខនិមិត្ត ។
  - o ក្នុងការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃ គណបក្សនយោបាយនីមួយៗ ត្រូវគណនា ដល់ចំនួន ទសភាគគឺ ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ណា ដែលមានមធ្យមភាគខ្ពស់ជាងគេ ។
  - o បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗរួចហើយត្រូវ ធ្វើការប្រៀបធៀបគ្នា ។ បញ្ជីបេក្ខជននៃគណបក្ស នយោបាយណាមានមធ្យមភាគធំជាងគេ ដែល ជាមធ្យមភាគខ្ពស់បំផុត (គិតទាំងចំនួនទសភាគ ពីរខ្ទង់ក្រោយក្បៀស) ត្រូវទទួលបាន អាសនៈ ១ (មួយ)[១៨] ។

[១៨] បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៤.៤-៤.៦ ទំព័រ ២៧-៣១

# ជំពូកទី២

# ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់

# ជំពូកទី២

# ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ / សង្កាត់

## ផ្នែកទី១. ការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះជ្រើសរើសក្រុមប្រឹក្សាឃុំ / សង្កាត់

### ១.១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត ។
- ចេះអាន និងសរសេរអក្សរខ្មែរ ។
- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ។
- មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើស កបឃ.ស[១៩] ។

### ១.២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

ក. ហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស កបឃ.ស ចំពោះ ៖

១. សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម ។

២. អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៣. សមាជិក គ.ជ.ប គធ.ខប គឃ.សប គ.ក.ប បុគ្គលិកបម្រើការងារក្នុង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៤. មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង

៥. ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ ។

៦. ស្មៀនឃុំ សង្កាត់ណាមួយ[២០]។

ខ. មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

---

[១៩] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៦.១ ទំព័រ ៧៤

[២០] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៦.២ ទំព័រ ៧៤

១. ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាពទៅបម្រើការក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងឋានៈនេះ សាមីខ្លួនត្រូវមានសិទ្ធិឡើងថ្នាក់ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍។

២. នៅពេលចប់អាណត្តិជាសមាជិក កបឃ.ស សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

៣. លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬអង្គភាព អាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។ ក្នុងករណីមិនអាចធ្វើទាន់ ត្រូវធ្វើពាក្យសុំច្បាប់ឈប់ពិសេសជូន គឃ.សប ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើកយុទ្ធនាការឃោសនាបោះឆ្នោត។ លិខិតបញ្ជាក់ ការអនុញ្ញាតច្បាប់ឈប់ពិសេសត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះសាមីជនដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬអង្គភាពដែលសាមីជនកំពុងបម្រើការងារ កាលបរិច្ឆេទសុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំរបស់ខ្លួន ពោលគឺនៅថ្នាក់លើមួយថ្នាក់ដែលខ្លួននៅក្រោមឱវាទ[២១]។

គ. បន្ទាប់ពីនាយករដ្ឋមន្ត្រីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើស កបឃ.ស តាមលក្ខខណ្ឌដូចខាងក្រោម

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំ ម្តង ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។ កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុង មករយៈពេល ០៩ (ប្រាំបួន) ខែ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ។ ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ ហើយត្រូវបានផ្សព្វផ្សាយនៅក្នុងឃុំ សង្កាត់នីមួយៗនូវកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើស កបឃ.ស កាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជននិងទីកន្លែង[២២]។

ឃ. ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស កបឃ.ស ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

១. បញ្ជីបេក្ខជននីមួយៗ ត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។

២. បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង។

៣. បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។ បេក្ខជនម្នាក់ៗ មិនត្រូវបានអនុញ្ញាតឱ្យលាឈប់ពីបេក្ខភាពមុនបញ្ជីបេក្ខជនផ្លូវការត្រូវបានសម្រេចឡើយ[២៣]។

[២១] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៦.៣ ទំព័រ ៧៥

[២២] មាត្រា ៣ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់នេះ

[២៣] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៦.៥ ទំព័រ ៧៦

ង. ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់ គ.ជ.ប ទៅ គឃ.សប យ៉ាងតិច៩០ (កៅសិប)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

១. គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនិងសេចក្ដីសម្រេចរបស់ គឃ.សប (ទ.១០០៨) ចំនួន ២ (ពីរ) ច្បាប់ ។ ពាក្យសុំចុះបញ្ជីបេក្ខជននេះ ត្រូវបានផ្ដល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយដែលមានបំណងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២. ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះ មានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត ។

៣. ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ ៖

- សេចក្ដីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ចំនួន១ (មួយ)ច្បាប់
- អាសយដ្ឋាននៃទីស្នាក់ការកណ្ដាលគណបក្សនយោបាយអាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់និងឈ្មោះតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ ដែលបានដាក់ស្នើបញ្ជីបេក្ខជន ។
- បញ្ជីរាយនាមបេក្ខជនចំនួន ៧ (ប្រាំពីរ) ច្បាប់ ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹង ២ (ពីរ) ដងនៃចំនួនសមាជិក កបឃ.ស ។

❖ **គឃ.សប ត្រូវរក្សាឱ្យបានបញ្ជីរាយនាមបេក្ខជនទាំង ៧ (ប្រាំពីរ) ច្បាប់ ដើម្បីប្រើប្រាស់ ៖**

- ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន
- ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប ជាបញ្ជីបេក្ខជនដំបូង
- ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប ជាបញ្ជីបេក្ខជនផ្លូវការ
- ១ (មួយ) ច្បាប់ តម្កល់ទុកជាឯកសារនៅ គឃ.សប
- ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប
- ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ (មួយ) ច្បាប់ ជូនសាមីគណបក្សនយោបាយ ។

- លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ ពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោតដោយបញ្ជាក់ឱ្យបានច្បាស់អំពីនាមត្រកូល នាមខ្លួន និងអាសយដ្ឋាន ។ មេឃុំ ចៅសង្កាត់ត្រូវចេញលិខិតបញ្ជាក់ជូនតាមការស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំ ដោយផ្អែកលើបញ្ជីបោះឆ្នោតផ្លូវការ។
- ជីវប្រវត្តិសង្ខេប និងសេចក្ដីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជនដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ចំនួន ៣ (បី) សន្លឹកទៀត ទំហំ ៤គុណ៦ ថតចំពីមុខ តាមគំរូរូបថតធ្វើ អ.ខ ។

❖ **ការប្រើប្រាស់រូបថតរបស់បេក្ខជននៃគណបក្សនយោបាយនីមួយៗ ៖**

- ១ (មួយ) សន្លឹក សម្រាប់បិទផ្សាយជាមួយបញ្ជីបេក្ខជនបន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនរួច នៅទីស្នាក់ការគឃ.សប
- ១ (មួយ) សន្លឹក សម្រាប់បិទជាបញ្ជីបេក្ខជនដំបូងនៅទីស្នាក់ការ គឃ.សប
- ១ (មួយ) សន្លឹក សម្រាប់បិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅទីស្នាក់ការ គឃ.សប ។

❖ **របៀបបិទរូបថតបេក្ខជន៖**

គឃ.សប ត្រូវបិទរូបថតតាមលេខរៀងឈ្មោះបេក្ខជននៃគណបក្សនយោបាយនីមួយៗលើក្រដាសដែលមានទំហំសមស្របទៅតាមចំនួនបេក្ខជន ។ លិខិតសន្យារបស់បេក្ខជនឈរឈ្មោះបោះឆ្នោតដែលជាមន្រ្តីរាជការថានឹងផ្តល់ច្បាប់សុំឈប់ពិសេសជូន គឃ.សប ។

ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ[២៤]។

## ១.៣. ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ.សប

គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់នីមួយៗ ។

- ➢ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៅគ្រប់ទីស្នាក់ការ គឃ.សប ។
- ➢ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ បរិក្ខារកុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀត ដល់គឃ.សប សម្រាប់បម្រើឱ្យការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ចូលទិន្នន័យពាក់ព័ន្ធនឹងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។
- ➢ ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ៣ (បី) ថ្ងៃ គឺរៀងរាល់ថ្ងៃ ព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១១:៣០នាទី រសៀលចាប់ពីម៉ោង២:០០នាទី ដល់ម៉ោង ៥:៣០នាទី ។
- ➢ គឃ.សប ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន និងរក្សាគល់បញ្ជី ១ (មួយ) ច្បាប់ ទុកជាឯកសារ ។
- ➢ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារដែលបានទទួលចុះកាលបរិច្ឆេទប្រគល់ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ទទួល ។ បន្ទាប់មក គឃ.សប ត្រូវបញ្ចូលព័ត៌មានរបស់គណបក្សនយោបាយនិងស្កេនបង្កាន់ដៃទទួលពាក្យនោះបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។
- ➢ នៅពេលបញ្ចប់ការទទួលពាក្យ គឃ.សប ត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ឃុំសង្កាត់របស់ខ្លួនចំនួន ៤ (បួន) ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខាឈ្មោះ និងបោះត្រា គឃ.សប រួចបិទផ្សាយ ១ (មួយ) ច្បាប់ នៅទីស្នាក់ការ គឃ.សបផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន ។

[២៤] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៦.៦ ទំព័រ ៧៦

• បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន គឃ.សប ត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ១ (មួយ) ថ្ងៃ ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន ។

• ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់មានសិទ្ធិផ្តល់មតិចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបិទផ្សាយខាងលើមក គឃ.សប សម្រាប់ជាមូលដ្ឋានពិចារណា មុនពេលសម្រេចយល់ព្រម ឬបដិសេធការសុំចុះបញ្ជីបេក្ខជន[២៥] ។

## ១.៤. ការពិនិត្យ និងសម្រេចរបស់ គឃ.សប លើពាក្យសុំចុះបញ្ជីបេក្ខជន

គឃ.សប ត្រូវពិនិត្យ និងសម្រេចយល់ព្រម ឬបដិសេធលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់ គណបក្សនយោបាយតាមលក្ខខណ្ឌទាំងឡាយ នៃ ប.ន.ឃ.ស នេះ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពី ថ្ងៃបានទទួលពាក្យសុំចុះបញ្ជីបេក្ខជន ។

គឃ.សប ត្រូវបញ្ចូលទិន្នន័យបេក្ខជននៃគណបក្សនយោបាយផ្អែកតាមបញ្ជីបានយកអោយនាមបេក្ខជនដែលបានភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប (ទ.១០០៨) ដោយត្រូវទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់លក្ខខណ្ឌរបស់បេក្ខជននៃគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន ។

ក្នុងករណីគណបក្សនយោបាយណាមួយ បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ ដូចបានកំណត់ខាងលើ គឃ.សប ត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជី បេក្ខជននោះ ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជន និងសេចក្តីសម្រេច របស់ គឃ.សប (ទ.១០០៨) ទាំង ២ (ពីរ) ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា រួចជូនទៅសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់ និង រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

- ករណីឃុំ សង្កាត់ណាមួយត្រូវបាន គឃ.សប សម្រេច យល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលបានដាក់ពាក្យសុំទាំងអស់ក្នុងឃុំ សង្កាត់នោះ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជន ដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម ។
- ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពី បេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។
- ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុចខាងលើបន្ទាប់បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជី បេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់ ។ បញ្ជី បេក្ខជនដំបូង

[២៥] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៦.៧ ទំព័រ ៧៩

ក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ.សប ត្រូវ បិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជី បេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ ។

- គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀង បញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្ដី រាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ឧប ។

ក្នុងករណីគណបក្សនយោបាយណាមួយ បំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គឃ.សប ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងណែនាំដល់គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជី បេក្ខជននោះឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ ហើយផ្ដល់ឱកាសឱ្យគណបក្សនយោបាយនោះធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ។

ក្នុងករណីគណបក្សនយោបាយ ដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពី គឃ.សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាត បានកែតម្រូវ ត្រឹមត្រូវ និងទាន់ពេលវេលាហើយនោះ គឃ.សប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនដូចក្នុងចំណុច ២ ក្នុងរយៈពេល ១ (មួយ) ថ្ងៃ បន្ទាប់ពី បានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ ។

- ក្នុងករណីគណបក្សនយោបាយទាំងអស់ដែល គឃ.សប ឱ្យ ធ្វើការកែតម្រូវនូវចំណុចខ្វះខាត បានកែតម្រូវត្រឹមត្រូវ ហើយ ត្រូវបាន គឃ.សប សម្រេច គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម។
- ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។
- ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុចខាងលើបន្ទាប់បើ គ.ជ.ប មិនបានទទួលពាក្យបណ្ដឹងជំទាស់អំពីបេក្ខជន ឬបញ្ជី បេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្ដឹងជំទាស់ ។ បញ្ជី បេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ.សប ត្រូវ បិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជន ផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ។
- គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀង បញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្ដី រាយការណ៍ ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ទៅ គ.ជ.ប តាមរយៈ គធ. ឧប ។

ក្នុងករណីគណបក្សនយោបាយដែលដាក់ស្នើបញ្ជីបេក្ខជនមិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងពេលវេលា គឃ.សប ត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជននោះ។

ក្នុងការសម្រេចបដិសេធ គឃ.សប ត្រូវ ៖

- ➢ បំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ រួចផ្ញើជូន ៖

- សាមីគណបក្សនយោបាយ ឬតំណាង ១ (មួយ) ច្បាប់
- គធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកឯកសារ ១(មួយ) ច្បាប់។

ប្រគល់ពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ជូនដល់សាមី គណបក្សនយោបាយ ឬតំណាងដែលបានដាក់ស្នើបញ្ជីបេក្ខជន សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាទៅ គធ.ឧប[២៦] ។

គណបក្សនយោបាយណាដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយត្រូវបាន គឃ.សប បដិសេធ សាមីគណបក្សនយោបាយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅ គធ.ឧប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ។ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ប៉ុន្តែសាមីគណបក្សនយោបាយ ឬតំណាងពុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅ គធ.ឧប តាមពេលវេលាទេនោះ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា។ ក្នុងករណីមានពាក្យបណ្តឹងតវ៉ា គធ.ឧប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹងតវ៉ាពីសាមីគណបក្សនយោបាយ ឬតំណាង ។ គធ.ឧប ត្រូវបិទផ្សាយជា សាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលត្រូវបើកសវនាការ។ ក្នុងករណីសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា គធ.ឧប ត្រូវបំពេញសម្រង់ សេចក្តីសម្រេច (ទ.១២០៣) ជា ៤ (បួន) ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ច្បាស់លាស់ រួចផ្ញើជូន ៖

- អ្នកប្តឹងតវ៉ា ១ (មួយ) ច្បាប់
- គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- គ.ជ.ប ដើម្បីជ្រាបជាព័ត៌មាន ១ (មួយ) ច្បាប់
- ឧបាង្គចបាដើម្បីម៉ាត្រូវាលាញ់ឯកសារ ១ (មួយ) ច្បាប់ ។

ក្នុងករណីទទួលបានសម្រង់សេចក្តីសម្រេច (ទ.១២០៣) គឃ.សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននៃ គណបក្សនយោបាយនោះ និងត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូន សាមីគណបក្សនយោបាយ ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជននៃ គណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប (ទ.១០០៨) ទាំង ២ (ពីរ) ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបានតាមរួចបានទៅសាមី គណបក្សនយោបាយ ១ (មួយ) ច្បាប់ និងរក្សាទុក មួយ ច្បាប់[២៧] ។

## ១.៥. ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

[២៦] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៦.១០ ទំព័រ ៨០

[២៧] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៦.១១ ទំព័រ ៨៣

គឃ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប ។

- ផ្អែកលើបញ្ជីបេក្ខជនផ្លូវការ គឃ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់ លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។
- ការចាប់ឆ្នោតត្រូវធ្វើឡើងជាសាធារណៈ ។ គឃ.សប ត្រូវបិទផ្សាយជា សាធារណៈអំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោង មុននឹងចាប់ផ្តើមធ្វើពិធីចាប់ឆ្នោត ។
- លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់របស់ខ្លួន និងដែលមាន ចុះហត្ថលេខារបស់អ្នកទទួលសម្រាប់ទុកជាឯកសារយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោង មុនពិធីចាប់ឆ្នោត ។
- របៀបវារៈនៃពិធីចាប់ឆ្នោតមាន ដូចខាងក្រោមនេះ ៖
    - o សុន្ទរកថាបើកពិធី ថ្លែងដោយប្រធាន គឃ.សប ។
    - o ការបង្ហាញសន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត និងស្រោមសំបុត្រ ។
    - o ការចាប់ឆ្នោតត្រូវធ្វើដោយព្រះសង្ឃ ឬឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលមានជំហរអព្យាក្រឹត និងដែលអាច ទទួលយកបានពីគ្រប់គណបក្សនយោបាយ ។
    - o ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត ។
    - o ការបិទពិធីចាប់ឆ្នោត ។
- គឃ.សប ត្រូវរៀបចំក្រដាសសមួយសន្លឹកសម្រាប់គណបក្សនយោបាយនីមួយៗ ។
    - o ក្រដាសនេះមានប្រភេទដូចគ្នា និងទំហំប៉ុនគ្នា ។
    - o ត្រូវរៀបចំក្រដាសមួយសន្លឹកសម្រាប់គណបក្សនយោបាយនីមួយៗ។
    - o ក្រដាសនេះមានប្រភេទដូចគ្នា និងមានទំហំប៉ុនគ្នា។
    - o ត្រូវសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយជាអក្សរ ដែលមានពណ៌ និងប្រភេទតួអក្សរដូចគ្នា និងមានទំហំប៉ុនគ្នានៅលើក្រដាសនេះ។
    - o ក្រដាសដែលបានសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយនីមួយៗរួចហើយ ត្រូវក្លាយទៅជាសន្លឹកឆ្នោតរបស់ គណបក្សដែលនឹងត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រ ដែលមានទំហំប៉ុនគ្នា ពណ៌ដូចគ្នា រួចមូរ និងចងកៅស៊ូកងពណ៌ដូចគ្នា ។
- មុនចាប់ផ្តើមការចាប់ឆ្នោត គឃ.សប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្ស នីមួយៗនៅចំពោះមុខអង្គពិធីមុននឹងបត់ដាក់ចូល និងបិទភ្ជិតស្រោមសំបុត្រ។
    - o សន្លឹកឆ្នោតនីមួយៗ ត្រូវបត់ជា ២(ពីរ) ផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្ររួចបិទជិត រួចមូរ និងចងកៅស៊ូកងពណ៌ដូចគ្នា។
    - o ស្រោមសំបុត្រឆ្នោតទាំងអស់ ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងប្រអប់ឬឡាំងតែមួយ ហើយត្រូវក្រឡុកប្រអប់ ឬឡាំងឆ្នោតនោះ។

- o បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬចាស់ព្រឹទ្ធាចារ្យ ឬអញ្ជើញឥស្សរជនចូលនិវត្តន៍ ដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌ ដើម្បីចាប់យកស្រោមសំបុត្រឆ្នោតម្តងមួយៗពីប្រអប់ ឬឡាំងឆ្នោត ។
- o ស្រោមសំបុត្រឆ្នោតដែលចាប់បានត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោត ម្នាក់ក្នុងចំណោម ២ (ពីរ) នាក់ ដែលជាសមាជិក គឃ.សប ។
- o សមាជិក គឃ.សប ១ (មួយ) នាក់ ត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្ស នៅចំពោះមុខអង្គពិធី ហើយ ជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទីពីរ ។
- o សមាជិក គឃ.សប ១ (មួយ) នាក់ទៀត ត្រូវអានឈ្មោះ គណបក្សនយោបាយ ដែលសរសេរនៅលើសន្លឹកឆ្នោតឱ្យ បានឮ និងសរសេរលេខរៀង "លេខ ១" នៅលើសន្លឹកឆ្នោតនោះ ហើយត្រូវបន្តធ្វើការចាប់ឆ្នោត និងចុះលេខរៀងតាមលំដាប់ រហូតដល់សន្លឹកឆ្នោតចុងក្រោយបង្អស់ ។

- សមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាលត្រូវបញ្ចូលទិន្នន័យលទ្ធផលលំដាប់លេខរៀងទៅក្នុងប្រព័ន្ធកុំព្យូទ័រ ហើយបោះពុម្ពកំណត់ហេតុនៃការចាប់ឆ្នោត កំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត (ទ.១១២១) ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្សដែលបានចុះលេខរៀងហើយ ដូចមានចែងក្នុងចំណុចខាងលើបន្ទាប់ រួចចុះហត្ថលេខា និងដាក់ជូនប្រធាន គឃ.សប ចុះហត្ថលេខា ។ តំណាងគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខានៅលើកំណត់ហេតុនេះបាន[២៨] ។

# ផ្នែកទី២. ការឃោសនាបោះឆ្នោត

## ២.១. បញ្ញាត្តិទូទៅនៃការឃោសនាបោះឆ្នោត

អនុលោមតាម ច.ប.ឃ.ស ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជីបេក្ខជន និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកបោះឆ្នោត ។ ការឃោសនាបោះឆ្នោតគឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។

### ក. សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជន ឬ គណបក្សនយោបាយណាមួយ

- ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន។
- ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំ សង្កាត់ យ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។
- ការជួបជុំ ឬការឃោសនាតាមផ្ទះ។
- ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។

[២៨] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៦.២០ ទំព័រ ៨៨

- ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេងឬតាមរយៈការចាក់ផ្សាយកាសែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌីក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ ។
- សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា ។
- សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ដើម្បីឱ្យអ្នកបោះឆ្នោត បោះឆ្នោតឱ្យខ្លួន ឬគណបក្សនយោបាយរបស់ខ្លួន ។
- សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬអ្នក សម្លៀកបំពាក់សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬ/និងបេក្ខជនជូនអ្នកបោះឆ្នោត។
- សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទប្រកាសផ្សាយពីគោលនយោបាយរបស់គណបក្សនយោបាយ ឬបេក្ខជន ។
- ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោតដើម្បីផ្សព្វផ្សាយគាំទ្របេក្ខជនណាម្នាក់ គណបក្សនយោបាយណាមួយ ។
- ការរៀបចំកម្មវិធីប្រកួតកីឡាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់[២៩] ។

**ខ. ពេលវេលា និងរយៈពេលនៃការឃោសនាបោះឆ្នោត**

ការឃោសនាបោះឆ្នោតត្រូវបើករយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត ។

គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់) យប់ ។ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ៦ (ប្រាំមួយ) ព្រឹក ។

សកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍បំពងសំឡេង ត្រូវបានកំណត់ដូចខាងក្រោម៖

- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២ (ពីរ) រសៀល
- ត្រូវហាមឃាត់នៅក្បែរមន្ទីរពេទ្យ
- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងពេលម៉ោងសិក្សាលើកលែងតែនៅក្រៅពេលម៉ោងសិក្សា ។

រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត ត្រូវបញ្ឈប់ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត ។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម៖

- ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង
- រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ

[២៩] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.១ ទំព័រ ៩៣

- ការគោរពសិទ្ធិ សេរីភាពបុគ្គល
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត
- ការមិនបង្កឱ្យមានអសន្តិសុខ ភាពចលាចល ឬការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឱ្យរាំងស្ទះ ឬរាំងរាំងក្នុងដំណើរការបោះឆ្នោត
- លទ្ធផលដែលបានមកពីការស្ទង់មតិត្រូវបញ្ជាក់អំពីប្រភពផ្តល់ព័ត៌មាន

ពេលវេលា ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសមកស្ទង់មតិ កម្រិតលម្អៀងនៃលទ្ធផល ព្រមទាំងត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព ។

គ្រប់សកម្មភាពឃោសនាដែលមាន នេះ ត្រូវបញ្ឈប់ទាំងអស់ក្នុងអំឡុងពេល ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ។ជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះ នឹងត្រូវទទួលការពិន័យតាម ច.ប.ឃ.ស[៣០] ។

### គ. ការធ្វើស្លាកសញ្ញាគណបក្សនយោបាយ

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិលើកស្លាកសញ្ញាគណបក្ស ឬ បិទផ្សាយឯកសារឃោសនាបោះឆ្នោតបម្រើឱ្យគោលដៅ ឃោសនាបោះឆ្នោតបាននៅទីសាធារណៈ ឬនៅទីស្នាក់ការរបស់ខ្លួន ឬទីកន្លែងឯកជន ឬលំនៅឋានឯកជន ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

- ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនាសម្រាប់គណបក្សនយោបាយមិនត្រូវអនុញ្ញាតឱ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ ។
- ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន ។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណរបស់គណបក្សណាមួយបាន ។
- ស្លាកសញ្ញា ឬសម្ភារឃោសនារបស់គណបក្សនយោបាយដែលស្ថិតនៅក្នុងរង្វង់ ១០០(មួយរយ) ម៉ែត្រពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុត នៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

[៣០] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.២ ទំព័រ ៩៤

- គណបក្សនយោបាយ ត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត[៣១] ។

**ឃ. ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត**

ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

- ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនជាសម្បត្តិរបស់រដ្ឋដែលមានស្លាកលេខ ឬដោះស្លាកលេខចេញ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនជាសម្បត្តិរបស់រដ្ឋដែលមានស្លាកលេខ ឬដោះស្លាកលេខចេញ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។
- មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋត្រូវបានកំណត់ដូចជា រថយន្តត្រីចក្រយានយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬ/និងរដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល។
- ការដឹកជញ្ជូនមានលក្ខណៈប្រមូលផ្តុំ ឬរៀបចំទុកជាមុន ត្រូវហាមឃាត់លើកលែងតែករណីចាំបាច់មានការសម្រេចផ្សេងពីនេះដោយ គ.ជ.ប[៣២] ។

**ង. ការស្លៀកពាក់ និង ការហែក្បួនឃោសនាបោះឆ្នោត**

❖ ការស្លៀកពាក់

ការស្លៀកពាក់ (សម្លៀកបំពាក់-មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា សារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬខាងក្រៅនៃការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

❖ ការហែក្បួនឃោសនាបោះឆ្នោត

គណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតយ៉ាងច្រើន ២ (ពីរ) ដង នៅក្នុងឃុំ សង្កាត់ដែលគណបក្សមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

១. ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ ដូចខាងក្រោម ៖

[៣១] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.៣ ទំព័រ ៩៥

[៣២] បទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.៤ ទំព័រ ៩៦

- ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ដែលសាមីគណបក្សនយោបាយបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។
- ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឆ្លងឃុំ សង្កាត់ ។
- ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំដូចខាងក្រោមៈ
  - ➢ មានការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗ ភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទនិងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេងមានអ្នកចូលរួមចាប់ពី ២០ (ម្ភៃ) នាក់ឡើងទៅ ដោយប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ ក្នុងការឃោសនាបោះឆ្នោត មានដូចខាងក្រោម ៖
  - o រថយន្តចាប់ពី ២ (ពីរ) គ្រឿងឡើងទៅ អមដោយទោចក្រ-យានយន្ត ឬ/និងត្រីចក្រយានយន្ត ចាប់ពី ១០ (ដប់)គ្រឿងឡើងទៅ
  - o ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ចាប់ពី ២០(ម្ភៃ) គ្រឿង
  - o ជលយានគ្រប់ប្រភេទចាប់ពី ៥ (ប្រាំ) គ្រឿងឡើងទៅ ។

២. គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ.សប យ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃមុនថ្ងៃហែក្បួនឃោសនា ។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីៈ

- នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ ។
- កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន ។
- ទីតាំងប្រមូលផ្តុំ និងតម្រាយផ្លូវដែលត្រូវហែក្បួន ។
- ចំនួនអ្នកចូលរួម ។
- ចំនួនយានជំនិះតាមប្រភេទនីមួយៗ ។

៣. ក្នុងករណីគណបក្សនយោបាយមានបំណងហែក្បួនឃោសនាឆ្លងកាត់ឃុំសង្កាត់ពីរ ឬច្រើនដែលមានព្រំប្រទល់ជាប់គ្នា ដែលសាមីគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត សាមីគណបក្សនយោបាយនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ.សប ពាក់ព័ន្ធយ៉ាងហោច
ឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនា ។ ឃុំ សង្កាត់ពាក់ព័ន្ធដែលសាមីគណបក្សនយោបាយបានហែក្បួនឆ្លងកាត់នោះ ត្រូវចាត់ទុកជា បានហែមួយដងរួចហើយ ។

៤. គឃ.សប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីសម្របសម្រួលទីកន្លែងផ្លូវ ពេលវេលា និងកម្មវិធីនៃការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ។

៥. ក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ត្រូវរក្សានូវសណ្តាប់ធ្នាប់ល្អ តាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក[៣៣] ។

**ច. លក្ខខណ្ឌសម្រាប់ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិនិងមន្ត្រីតុលាការ ក្នុងសកម្មភាពឃោសនា**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិនិងមន្ត្រីតុលាការ អាចធ្វើបាន និងមិនត្រូវធ្វើក្នុងសកម្មភាពឃោសនាដូចជា៖

១. ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យ គំរាមកំហែងដល់អាយុជីវិតរូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។

២. ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៣. ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់ឡើយ ។ ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ ដូចតទៅ៖

- ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុះហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និង បេក្ខជនណាម្នាក់ ។
- ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការធ្វើសកម្មភាពចែកចាយសម្ភារដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណបក្សយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។
- ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៤. បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

[៣៣] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.៥, ៧.៦ ទំព័រ ៩៧

ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ ។

៥. ក្នុងដំណើរការបោះឆ្នោត មេភូមិ និងជំនួយការមេភូមិ ត្រូវអនុវត្តតួនាទី និងកាតព្វកិច្ចរបស់ខ្លួនស្របតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅណែនាំស្តីពីភារកិច្ច និងកាតព្វកិច្ចរបស់មេភូមិ និងជំនួយការមេភូមិ ក្នុងដំណើរការរៀបចំការបោះឆ្នោតរបស់ គ.ជ.ប ។ មេភូមិ និងជំនួយការមេភូមិ មានសិទ្ធិបញ្ចេញមតិយោបល់ផ្ទាល់ខ្លួន និងមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយដើម្បីគាំទ្រគណបក្សនយោបាយដែលខ្លួនជ្រើសរើស ។ ក៏ប៉ុន្តែសកម្មភាពទាំងនោះ ត្រូវធ្វើក្នុងឋានៈជាបុគ្គលឯកជន ពោលគឺមិនមែនក្នុងតួនាទីជាមេភូមិ និងជំនួយការមេភូមិហើយជំនួយការមេភូមិ ត្រូវព្យាយាមធ្វើឱ្យបាននូវសកម្មភាព ដូចខាងក្រោម៖

- ផ្តល់សេវា និងព័ត៌មានដូចគ្នាៗជូនដល់អ្នកភូមិទាំងអស់ ដោយមិនប្រកាន់និន្នាការនយោបាយ ដើម្បីបង្កើតបរិយាកាសជឿទុកចិត្តគ្នា ។
- ធានាថាការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងព័ត៌មានផ្សេងៗដទៃទៀតត្រូវបានអនុវត្តដោយយុត្តិធម៌ ដោយស្មើភាព និងអស់ពីកម្លាំងចិត្តដល់អ្នកភូមិគ្រប់ៗរូប និងដោយឥតគិតថ្លៃ ។
- ត្រូវប្រកាន់ខ្ជាប់ឥរិយាបថ អព្យាក្រឹត ឥតលម្អៀងនៅក្នុងការបំពេញការងារទាក់ទងនឹងដំណើរការរៀបចំការបោះឆ្នោត ។
- ត្រូវរាប់អាន ទទួលស្គាល់ និងអនុវត្តការងារចំពោះអ្នកភូមិគ្រប់ៗរូបឱ្យបានស្មើគ្នា ។
- ផ្តល់កិច្ចសហការជាមួយនឹង គឃ.សប គធ.ខប និង គ.ជ.ប ទាក់ទងនឹងការអនុវត្តការងារបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដូចជាការផ្តល់ព័ត៌មានអំពីការបោះឆ្នោត ការចែកខិត្តប័ណ្ណ សៀវភៅព័ត៌មាន ឬប័ណ្ណប្រកាសផ្សេងៗ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

❖ មេភូមិ និងជំនួយការមេភូមិ

ត្រូវជៀសវាងការគំរាមកំហែង ឬបង្ហាញឥរិយាបថលម្អៀងក្នុងការអនុវត្តការងាររបស់ខ្លួនទាក់ទងនឹងការបោះឆ្នោត ។ មេភូមិ និងជំនួយការមេភូមិមិនត្រូវអនុវត្ត ដូចខាងក្រោម៖

- បង្ហាញការគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយជាសាធារណៈ ។
- ប្រើប្រាស់ឥទ្ធិពល ឬតួនាទីរបស់ខ្លួនរំលោភលើសិទ្ធិសម្រេចរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបោះឆ្នោត ។

  ការរំលោភលើសិទ្ធិរួមមាន ៖
  - បំភិតបំភ័យ ឬគំរាមកំហែងអ្នកបោះឆ្នោតក្នុងគោលបំណង ឱ្យអ្នកបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
  - សួរនាំអ្នកបោះឆ្នោត ឬចង់ដឹងអំពីការបោះឆ្នោតជាសម្ងាត់របស់អ្នកបោះឆ្នោត ។
  - ដកហូត អ.ខ ឬ ឯ.អ ពីប្រជាពលរដ្ឋ ។
  - ជ្រៀតជ្រែកលើសិទ្ធិអ្នកបោះឆ្នោត ក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយសេរី ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់ ។

- o អូសទាញអ្នកបោះឆ្នោតឱ្យគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។រារាំងអ្នកភូមិគ្រប់រូបដែលមានបំណងចូលរួមក្នុងកិច្ចប្រជុំសាធារណៈរបស់ភូមិ ឃុំ សង្កាត់ ឬរបស់គណបក្សនយោបាយណាមួយ ឬរារាំងការទទួលព័ត៌មានពីគណបក្សនយោបាយណាមួយ ។
- ធ្វើសកម្មភាពណាមួយ ទោះដោយប្រយោលក្តី ឬផ្ទាល់ក្តី ដើម្បីបំភិតបំភ័យគំរាមកំហែងអ្នកបោះឆ្នោតដែលនាំឱ្យបាត់សេរីភាពនៃការជ្រើសរើសរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត ។
- ធ្វើជាអ្នកផ្សព្វផ្សាយឱ្យគណបក្សនយោបាយណាមួយ ដែលនាំឱ្យជះឥទ្ធិពលដល់អ្នកភូមិ និងបាត់បង់ភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយផ្សេងទៀត ។
- ផ្អិបទុកព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មានដោយមានការរើសអើង ចំពោះអ្នកគាំទ្រគណបក្សនយោបាយណាមួយ ។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើស កបឃ.ស ។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុកនិងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោមៈ

- ផ្តួចផ្តើម ឬចូលរួមនៅក្នុងការឃោសនារបស់គណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់ ។ ការផ្តួចផ្តើម ឬការចូលរួមឃោសនារួមមានៈ
  - o ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ បេក្ខជនណាម្នាក់ ។
  - o ការចូលរួមក្នុងក្បួនដង្ហែការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
  - o ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
  - o ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។
- ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរកឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ និងការបង្ហាញភាពលម្អៀង រួមមានៈ
  - o ការស្នង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
  - o ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់ ។
  - o ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
  - o ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

- ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្សរួមមានៈ
  - ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
  - ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗ ជូនប្រជាពលរដ្ឋសម្រាប់ចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
  - ការផ្តល់ថវិកា សម្ភារ និងបរិក្ខារ សម្រាប់ក្បួនដង្ហែឃោសនាការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ហាមជនបរទេស ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- មុននឹងបើកការឃោសនាបោះឆ្នោត គធ.ខប និង គឃ.សប ត្រូវផ្សព្វផ្សាយដល់មន្ត្រី តាមរយៈអាជ្ញាធរដែនដីកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការទាក់ទិនដល់ការឃោសនាបោះឆ្នោត ។

គធ.ខប និង គឃ.សប ត្រូវចាត់ចែងកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងប្រជុំបន្ថែម តាមការចាំបាច់ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បីៈ
  - ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត ។
  - ជម្រាបជូនជាសង្ខេបពី ប.ន.ឃ.ស ។
  - ស្តាប់មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេង
  - ពិភាក្សាលើបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត[៣៤] ។

### ឆ. ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវតែគោរពតាមវិធានបទប្បញ្ញត្តិ និងគោលការណ៍ដែលចែងក្នុង ច.ប.ឃ.ស និងក្រមសីលធម៌ គោរពតាម បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

- គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ ។

[៣៤] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.៧-៧.១៣ ទំព័រ ៩៩

- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវបង្កាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ ។
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ។
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់ឡើយ ។
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ ។
- គ្រប់គណបក្សនយោបាយ ឬបេក្ខជនឬតំណាងណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្តវិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័នអង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

## ជ. ការការពារចំពោះគណបក្សនយោបាយ ឬបេក្ខជន ឬតំណាង

គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះ ឱ្យឈប់គាំទ្រដល់បេក្ខជនឬគណបក្សនយោបាយដទៃទៀតឡើយ ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

- ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ
- ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម ។
- ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់ ។
- ការរំលោភដោយពាក្យសម្តីនឹងធ្វើទុក្ខទោសដល់រាងកាយ ។
- ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។
- ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល ដូចជា ឃាតកម្ម ការវាយដំការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់។
- ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

- ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យស្រណោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូន គ្រួសាររបស់ខ្លួន ។
- ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាចឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន ។
- ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជា ការបញ្ឈប់ពីការងារការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬធ្វើឱ្យខូចផលប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត
- ការប្រមូល ឬការដកហូត ឬការបំផ្លាញឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោត ។
- ការកំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្តាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា[៣៥]។

## ២.២. សម្ភារអប់រំអ្នកបោះឆ្នោត

អគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដែលមាននាយកដ្ឋានបណ្តុះបណ្តាលនិងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈជាសេនាធិការ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត និងសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការបោះឆ្នោត ។

- គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចូលរួមយ៉ាងសកម្ម ដើម្បីឱ្យការអប់រំសាធារណជនដែលទាក់ទងដល់ដំណើរការបោះឆ្នោតមានប្រសិទ្ធភាពខ្ពស់។
- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជនអំពីការបោះឆ្នោត អាចទាក់ទងព័ត៌មានជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតនិងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ។
- សម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវតែអព្យាក្រឹត និងមិនលម្អៀង ។ សម្ភារនោះមិនត្រូវគាំទ្រ ឬបណ្តុះបង្អាប់គណបក្សនយោបាយ ហើយត្រូវគោរពទៅតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។
- សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំដែលផលិតដោយ គ.ជ.ប និងសម្ភារអប់រំដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិឬ/និងអន្តរជាតិដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ ។
- ដើម្បីធានាថា ខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែន រដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេសនិងតាមច្បាប់បោះឆ្នោត ហើយនិងតាមបទបញ្ជា និង

[៣៥] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៧.១៤ ទំព័រ ១០៥

នីតិវិធីរបស់ គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រម និងណែនាំដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារអប់រំនេះ។

- ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ ។
- ទោះបីជាសម្ភារអប់រំត្រូវបានទទួល ឬមិនបានទទួលលិខិតយល់ព្រមក៏ដោយអ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារអប់រំនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ ។ ម្ចាស់សម្ភារអប់រំត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។
- ក្នុងករណីដែលមានការស្នើសុំការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោលបាយ មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រម ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលបានសំណើពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា សុំឱ្យជួយពិនិត្យផ្ទៀងផ្ទាត់ សម្ភារអប់រំនោះ ។ ក្នុងករណីពិនិត្យឃើញថា សម្ភារ ឬខ្លឹមសារអប់រំមិនសមស្របតាមច្បាប់ បទបញ្ជានិងនីតិវិធីទេ គណៈកម្មការសម្របសម្រួលត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវនិងប្រគល់ឱ្យគណៈកម្មការសម្របសម្រួល ពិនិត្យឡើងវិញ ។ ក្នុងករណីគណៈកម្មការសម្របសម្រួល ធ្វើការពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេល ៧២(ចិតសិបពីរ) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន ។
- សម្ភារអប់រំដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពីគ.ជ.ប ដូចជា ៖
    - ស្ប៉ុតវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ ។
    - កាសែតម៉ាញ៉េ ឬខ្សែអាត់សំឡេង ។
    - ខិត្តប័ណ្ណផ្សេងៗ និងបដា ។
    - សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត ។
    - ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន ។
    - រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក ។
- សម្ភារដែលបានពិនិត្យ ផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខ ១ (មួយ) ច្បាប់ សម្រាប់ជាឯកសារ ។
- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រម ដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវតាមបញ្ញត្តិនៃ ច.ប.យ.ស ។ ប្រសិនបើព័ត៌មានដែលមានក្នុងសម្ភារអប់រំ ដែលខ្លួនបានផលិតនោះត្រូវបានរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយពុំត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធី ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.យ.ស និង ប.ន.យ.ស គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារនោះ

ទាំងស្រុងតែម្តង ។ សម្ភារដែលរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ។

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស ។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋានមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតតែប៉ុណ្ណោះ[៣៦]។

## ២.៣. រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ

គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយ អាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាផ្សព្វផ្សាយបានដូចជា ៖

- ខិត្តប័ណ្ណឃោសនាបោះឆ្នោត ។
- ការឃោសនាតាមរលកអាកាស ឬតាមឧបករណ៍បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព
  - អត្ថបទឃោសនា ។
  - បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ ។
  - ការសូត្រកំណាព្យ ។
  - ការប្រគំតន្ត្រីនៅនឹងកន្លែង ។
  - សម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយយមិនបន្តផ្ទាល់ ។
  - ការសម្តែងសិល្បៈ ។
  - ការចាក់ផ្សាយកាស្សែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូជាសាធារណៈ ឬទីធ្លាសាធារណៈ ។
  - ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្លូវការរបស់ខ្លួន ។
- ដោយយោងលើរូបភាព និងសម្ភារឃោសនាបោះឆ្នោត ដូចបានបញ្ជាក់ខាងលើ មធ្យោបាយផ្សេងៗទៀតរួមមាន៖
  - រឿងល្ខោនខ្លីៗ និងការសម្តែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្តវីដេអូ។
  - ប៉េងប៉ោង ឬ/និងបង្ហោះខ្លែង ។
  - សម្ភារបោះពុម្ពមានជាអាទិ៍ រូបភាពបិទផ្សាយសម្លៀកបំពាក់អាវយឺត មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមរថយន្តស្លាកសញ្ញា លោហៈខ្វាស់ បដា ។
  - ការស្រែកតាមទីសាធារណៈ ។

[៣៦] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.១៦ ទំព័រ ១០៧

- គ្រប់សម្ភារ ឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយឬផ្សព្វផ្សាយដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសម្គាល់របស់សាមីគណបក្ស (ឈ្មោះ ឬ/និងអាសយដ្ឋាន) [៣៧]។

## ២.៤. ភារកិច្ច និងភាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត ។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងពាក់ព័ន្ធដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោត ជូនសាធារណជន ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ឯកជន ដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ត្រូវអនុវត្តតាមក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងរដ្ឋ ទាំងឯកជន ត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

រាល់ពាក្យបណ្ដឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី ១៤ នៃប.ន.ឃ.ស នេះ[៣៨] ។

[៣៧] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.១៧ ទំព័រ ១១១

[៣៨] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៧.២៤-៧.២៧ ទំព័រ ១១៧

# ជំពូកទី៣

# ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត

# ជំពូកទី៣

# ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត

## ផ្នែកទី១. ការបោះឆ្នោត

### ១.១ ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

អនុលោមតាមមាត្រា ៥៣ និងមាត្រា ៩៤ នៃ ច.ប.ត.រ គ.ជ.ប ត្រូវបោះពុម្ព បិទផ្សាយជាសាធារណៈ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅទីស្នាក់ការ គឃ.សប យ៉ាងតិច ៣០ (សាមសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត។

គ.ជ.ប ត្រូវណែនាំដល់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យ ចាត់ចែងបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតខាងលើនេះបានទាន់ពេលវេលា ដោយត្រូវធានាថាបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំនីមួយៗត្រូវបានថតចម្លង និងផ្ញើជូន គឃ.សប ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើប្រាស់ដូចខាងក្រោម៖

- បិទផ្សាយ ១ (មួយ) ច្បាប់ នៅទីស្នាក់ការ គឃ.សប ៣០( សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ហើយត្រូវថែរក្សារហូត ថ្ងៃបោះឆ្នោតរក្សាទុកជាឯកសារនៅ គឃ.សប ១ (មួយ) ច្បាប់។

បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ ចំណុះរាជធានី ខេត្តនីមួយៗ ត្រូវបានថតចម្លងលើក្រដាស ឬ ក្នុងស៊ីឌីផ្ញើជូន គធ.ខប ពាក់ព័ន្ធ ដើម្បីរក្សាទុកជាឯកសារ និងបម្រើដល់សាធារណជន។

នាយកដ្ឋានប្រតិបត្តិការ ត្រូវសហការជាមួយនាយកដ្ឋានគ្រប់គ្រងទិន្នន័យ អ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ដើម្បីរៀបចំបញ្ជីឈ្មោះទីតាំងការិយាល័យ បោះឆ្នោត។

នាយកដ្ឋានប្រតិបត្តិការ ត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ជូននាយកដ្ឋានរដ្ឋបាល ១ (មួយ) ច្បាប់ ដើម្បីសហការគ្នាធ្វើជាសេនាធិការ ជូន គ.ជ.ប ក្នុងការកំណត់ចំនួនមន្ត្រីការិយាល័យបោះឆ្នោត ដើម្បីជ្រើសរើស សមាសភាព គ.ក.ប/គ.ក.រ[៣៩] ។

### ១.២. ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារៈ ឧបករណ៍ចាំបាច់សម្រាប់ការបោះឆ្នោត

គ.ជ.ប ត្រូវផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារឧបករណ៍សម្រាប់បម្រើឱ្យការបោះឆ្នោតតាម ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

- គ.ជ.ប ត្រូវធានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួនសម្រាប់រាជធានី ខេត្តនីមួយៗ នៅលើក្រដាសពណ៌ស។
- សន្លឹកឆ្នោតនីមួយៗ ត្រូវមានគល់បញ្ជីសន្លឹកឆ្នោត។ លេខរៀងតាមលំដាប់ តគ្នានៃសន្លឹកឆ្នោត ត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត។

[៣៩] បទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៩.១ ទំព័រ ១៤២

- សន្លឹកឆ្នោតនីមួយៗ ត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះ គណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់។ សញ្ញាសម្គាល់គណបក្ស នយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ ដែលត្រូវដាក់នៅលើសន្លឹកឆ្នោត ត្រូវដាក់តាមលំដាប់លំដោយ ផ្អែកតាម លទ្ធផលនៃការចាប់ឆ្នោត។
- រាជធានី ខេត្តនីមួយៗ ត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួន ដែល គ.ជ.ប ផ្តល់ជូន។
- គ.ជ.ប ត្រូវធានាផ្តល់ហិបឆ្នោតឱ្យបានគ្រប់ចំនួនសម្រាប់ឃុំ សង្កាត់នីមួយៗ។ គ្រប់ហិបឆ្នោតទាំងអស់ត្រូវ៖

- មានគម្របជាប់មកជាមួយ ដែលអាចចាក់បិទបានដោយប្រើប្រាស់ សោឃ្លុំមានលេខធានានូវសុវត្ថិភាព ដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបឆ្នោតបានប្រសិនបើមិនបើកគម្របមានសោ ឬ ឧបករណ៍ផ្សេងទៀតសម្រាប់កិបពេលបិទហិបឆ្នោត។
- មានស្លាកលេខ ឬសញ្ញាសម្គាល់នៅផ្នែកខាងក្រៅយ៉ាងច្បាស់ដែលមិនអាចដូរ ឬលុបបានដោយងាយ ហើយស្លាកលេខ ឬសញ្ញាសម្គាល់នេះត្រូវមានតែមួយគត់សម្រាប់ហិបឆ្នោតនោះនិងសម្គាល់បានថា ហិបឆ្នោតនោះទាក់ទងទៅនឹងឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតណាមួយ។

- គ.ជ.ប ត្រូវធានាឱ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នា សម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ។

គ.ជ.ប ត្រូវតាក់តែងបទបញ្ជា និងនីតិវិធីសម្រាប់ការប្រគល់ ទទួល និងការប្រគល់ត្រឡប់មកវិញ និងធានាភាពសម្ងាត់នៃត្រានេះ។

- គ.ជ.ប ត្រូវធានាឱ្យការិយាល័យបោះឆ្នោតនីមួយៗមានសម្ភារ ឧបករណ៍ដូចខាងក្រោម៖

១. បញ្ជីបោះឆ្នោត។

២. សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់។

៣. ហិបឆ្នោតដែលអាចចាក់ជាមួយសោឃ្លុំមានលេខ។

៤. បន្ទប់សម្ងាត់។

៥. ត្រា គ.ក.ប។

៦. ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។

៧. ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃសម្គាល់ថាបានបោះឆ្នោតហើយ។

៨. និងប្រដាប់ឃ្លុំ។

៩. ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល។

១០. ប៊ិកសរសេរដែលមានគុណភាពល្អ។

១១. ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ។

១២. កញ្ចប់ និងស្បោងប្លាស្ទិក។

១៣. សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត[៤០] ។

## ១.៣. ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ.

គ.ក.ប នឹងក្លាយទៅជា គ.ក.រ នៅពេលរាប់សន្លឹកឆ្នោត។ គ.ក.ប/គ.ក.រ នីមួយៗមានភារកិច្ច ចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុង ការិយាល័យបោះឆ្នោត និង ការិយាល័យរាប់សន្លឹកឆ្នោតដែល គ.ក.ប/គ.ក.រ នោះទទួលខុសត្រូវ។

ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិ ការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលខ្លួនទទួលខុសត្រូវ និងត្រូវៈ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការ បោះឆ្នោត និងការរាប់សន្លឹកឆ្នោត។
- ម្ចាស់ការ និងចាត់ចែងក្នុងការអនុវត្តគ្រប់ដំណើរការនៃការ បោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់គ.ជ.ប។
- ទទួលពិនិត្យផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់ សម្ភារ ឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតពិសេសពិនិត្យលេខកូដនៃកញ្ចប់សន្លឹកឆ្នោតដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ។
- រៀបចំទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់ សន្លឹកឆ្នោត ទៅតាមគំរូប្លង់ការិយាល័យបោះឆ្នោត និងរាប់ សន្លឹកឆ្នោត និងបំពាក់គ្រឿងសង្ហារឹម។
- តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់សមាសភាព គ.ក.ប/គ.ក.រ នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងអាណត្តិ របស់ខ្លួន។
- ដាក់ជំនួសតំណែងសមាជិក គ.ក.ប/គ.ក.រ ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា។
- ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុង ការិយាល័យបោះឆ្នោត។ ក្នុងពេលកំពុងដំណើរការបោះឆ្នោត យ៉ាងយូរ ១ (មួយ) ម៉ោងម្តង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីធ្វើអនាម័យសម្លាប់មេរោគ និងត្រួតពិនិត្យសុវត្ថិភាព សម្ភារ ដែលបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ក្នុងករណីគ្មាន អ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់។

[៤០] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៩.២ ទំព័រ ១៤៣

- ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបាន បំពេញ និងចុះហត្ថលេខាត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាជាសាក្សី។
- ត្រួតពិនិត្យលិខិតតែងតាំង និងទទួលស្គាល់ភ្នាក់ងារគណបក្ស នយោបាយ និងលិខិតតែងតាំង និងទទួលស្គាល់អ្នកសង្កេតការណ៍ដែលត្រូវចូលរួមសង្កេតមើលការបោះឆ្នោត និងការ រាប់សន្លឹកឆ្នោត។
- អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្លាស់ប្តូរទីកន្លែងពិនិត្យមើលដំណើរការបោះឆ្នោត ដោយ ត្រូវរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងធានាឱ្យបាននូវការសម្ងាត់នៃការបោះឆ្នោត។
- ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតដល់អ្នកដែលមានវត្តមាន នៅក្នុងការិយាល័យបោះឆ្នោត។
- បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត។
- ចាត់វិធានការនានា រៀបរយដើម្បីធានាឱ្យបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ និងការប្រព្រឹត្តទៅជាប្រក្រតីនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យ រាប់សន្លឹកឆ្នោត ព្រមទាំងបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតចាក់ ឬកាត់ផ្តាច់សោឃ្លុំការពារហិបឆ្នោត។
- ធានាឱ្យប្រាកដថាអ្នកបោះឆ្នោតម្នាក់ៗត្រូវបានណែនាំឱ្យចេះពីរបៀបបោះឆ្នោត និងតាមដានពិនិត្យមើល ប្រាកដថានៅពេលចេញពីបន្ទប់សម្ងាត់ ដើម្បីឱ្យ អ្នកបោះឆ្នោតបាន បត់សន្លឹកឆ្នោតតាមផ្នត់ដើមតាមការណែនាំ។
- ធានាឱ្យប្រាកដថា ការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះត្រូវតែបានអនុវត្តតាមការណែនាំ។
- ធានាឱ្យប្រាកដថា ការប្តឹងជំទាស់ ឬ/និងតវ៉ាក្នុងការិយាល័យ បោះឆ្នោតដោយភ្នាក់ងារគណបក្សនយោបាយ ស្របតាម មាត្រា ១១៤ នៃ ច.ប.ត.រ ត្រូវតែបានដោះស្រាយភ្លាម ដោយ អនុវត្តស្របតាម ប.ន.ត.រ និងការណែនាំរបស់ គ.ជ.ប។
- ជួយអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោត ដោយខ្លួនឯងបានតាមការស្នើសុំរបស់សាមីខ្លួន។
- ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត។
- ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្ស នយោបាយដែលបានទទួលសំឡេងឆ្នោត។
- ប្រគល់ជូន គឃ.សប នូវកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត(ទ.១១០៨) និង កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀត។
- ប្រគល់ជូន គឃ.សប នូវកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខឬកាលៈទេសៈមានអាសន្ន ដែលមិនអាចរាប់សន្លឹកឆ្នោតនៅ ការិយាល័យបោះឆ្នោតនោះបាន។
- បំពេញភារកិច្ចរបស់ខ្លួន ដោយជំហរអព្យាក្រឹត និងមិនលម្អៀង។
- បំពេញភារកិច្ចផ្សេងៗទៀតដែល គឃ.សប ប្រគល់ឱ្យ។

សមាជិកទី២ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/ គ.ក.រ និងត្រូវបំពេញភារកិច្ច ដូចខាងក្រោម៖

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការ បោះឆ្នោត និងរាប់សន្លឹកឆ្នោត។
- ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត តាមគំរូប្លង់ដែលកំណត់ដោយគ.ជ.ប។
- ជួយរកឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតដែលបិទ នៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀងឈ្មោះ របស់គាត់។
- ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុងករណីចាំបាច់ អាចផ្តល់បណ្ណលេខរៀងតាមលំដាប់អ្នកមក មុនមកក្រោយ) ព្រមទាំងរាយការណ៍ជូនប្រធាន គ.ក.ប អំពី ការរំខាន ឬការអុកឡុក ឬការរារាំង ឬការជ្រៀតជ្រែកនានា ក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត (ប្រសិនបើមាន)។
- រាយការណ៍ជូនប្រធាន គ.ក.ប ក្នុងករណីពិនិត្យឃើញថាមានអ្នកបោះឆ្នោតណាម្នាក់ បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។
- ប្រមូល អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោតដែលស្ថិតក្នុងបរិវេណ ខាងក្នុងនៃការិយាល័យបោះឆ្នោត នៅម៉ោង ១៥:០០ (ដប់ប្រាំ)រសៀល ប្រសិនបើមាន។
- ចោះ ឬកាត់សន្លឹកឆ្នោតដែលនៅសល់មិនបានប្រើប្រាស់បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត។
- សហការជាមួយសមាជិកទី៣ ក្នុងការការពារមាត់ទ្វារការិយាល័យ បោះឆ្នោត ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែង សណ្តាប់ធ្នាប់ក្នុងការិយាល័យបោះឆ្នោត និងការិយាល័យ រាប់សន្លឹកឆ្នោត។
- បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅមុខការិយាល័យរាប់សន្លឹកឆ្នោត។
- បញ្ជូនស្រោមសំបុត្រដែលមានដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និង ស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេល បោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមាន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុង ពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ទៅ គឃ.សប។
- បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប/ គ.ក.រ ប្រគល់ឱ្យ។

សមាជិកទី៣ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/ គ.ក.រ និងត្រូវបំពេញភារកិច្ច ដូចខាងក្រោម៖

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។
- ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត។
- ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

- ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរតាមលំដាប់មុនក្រោយ ត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គល ណែនាំ និង ប្រសិនបើគាត់ត្រូវបោះឆ្នោត នៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យ អ.ខ ឬ ឯ.អរបស់គាត់។
- អនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមានក្នុងការិយាល័យបោះឆ្នោត ចំនួន ៤ (បួន) នាក់ ក្នុងពេលតែមួយ។
- ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ចំពោះអ្នក បោះឆ្នោតជាព្រះសង្ឃ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនមានពិការភាព និងអ្នកមានជំងឺ បន្ទាប់ មកគឺអ្នកឈរខាងមុខគេក្នុងជួរ។
- ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោតដើម្បីឱ្យបានដឹងថាគាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត។
- ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការរំខាន ឬការអុកឡុក ឬការ រាំងស្ទះ ឬការជ្រៀតជ្រែក ជូនប្រធាន គ.ក.ប។
- សហការជាមួយសមាជិកទី២ ក្នុងការការពារសន្តិសុខនៅ ច្រកផ្លូវចេញចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។
- បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប/ គ.ក.រ ប្រគល់ឱ្យ[៤១] ។

## ១.៤. ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត

គ.ជ.ប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោត ត្រូវតែបានបញ្ជូន និងប្រគល់ជូន គ.ក.ប មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត។ នៅពេលព្រឹកថ្ងៃសៅរ៍មុនថ្ងៃ បោះឆ្នោត ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីធ្វើការត្រួតពិនិត្យសម្ភារឯកសារបោះឆ្នោត និងរៀបចំគំរូប្លង់ការិយាល័យបោះឆ្នោត។

១. គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារគ្រប់គ្រាន់សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតជូន គធ.ខប គឃ.សប និង គ.ក.ប ទាំងអស់។

២. នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋាន សេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវទទួលខុសត្រូវក្នុងការផលិតបញ្ជីបោះឆ្នោត ផ្លូវការចំនួន ៣ (បី) ច្បាប់ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ សម្រាប់បែងចែកជូន គឃ.សប និង គ.ក.ប ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

៣. នាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវ រៀបចំផែនការបែងចែក និងត្រៀមសម្ភារ ឯកសារសម្រាប់ដឹកជញ្ជូនទៅ កាន់គោលដៅនានា ដើម្បីបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឱ្យ បានគ្រប់គ្រាន់ជាមុន។ សម្ភារ ឯកសារសម្រាប់បម្រើការបោះឆ្នោត ការរាប់ សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតត្រូវបានរៀបចំដាក់ក្នុងហិបដែលរួមមាន ៤ (បួន) ប្រភេទគឺ៖

[៤១] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ៩.៣ ទំព័រ ១៤៤

- ហិបបរិក្ខារសម្រាប់បណ្តុះបណ្តាលដែលត្រូវបញ្ជូន និងប្រគល់ ជូននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតនៃ អគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ និង គធ.ខប។
- ហិបបរិក្ខារ គធ.ខប ដែលអាចមានមួយ ឬច្រើន ហើយត្រូវ បញ្ជូន និងប្រគល់ជូន គធ.ខប។
- ហិបបរិក្ខារ គឃ.សប ដែលអាចមានមួយ ឬច្រើន ហើយត្រូវ បញ្ជូន និងប្រគល់ជូន គឃ.សប។
- ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវបញ្ជូន និង ប្រគល់ជូន គ.ក.ប។

៤. នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវផ្គត់ផ្គង់សម្ភារបរិក្ខារកុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គធ.ខប និង គឃ.សប សម្រាប់ប្រើប្រាស់ក្នុង ការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៥. នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ទទួលហិបបរិក្ខារ និងសម្ភារៈផ្សេងៗ ដូចមានចែងក្នុងចំណុច ៣ និងចំណុច ៤ ខាងលើនេះមន្ត្រីដែលទទួលបន្ទុកការបញ្ជូនទៅតាមថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) និងត្រូវឱ្យមន្ត្រីដែលទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗចុះហត្ថលេខាបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ។

៦.ហិបបរិក្ខារ គធ.ខប ដែលត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ ដំណើរការបោះឆ្នោត ។

៧. ហិបបរិក្ខារ គឃ.សប ដែលត្រូវបញ្ជូន និងប្រគល់ជូន គឃ.សប សម្រាប់ប្រើប្រាស់ ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

៨. ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និង ប្រគល់ជូន គ.ក.ប នីមួយៗ មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោង មុនថ្ងៃបោះឆ្នោត។

៩. គ.ជ.ប ការបញ្ជូន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវធានាក្នុង គ.ក.ប នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត សាគួរសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨ ខាងលើនេះ។ គឃ.សប ត្រូវជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេត ការណ៍ ដើម្បីចូលរួមសង្កេតមើល គ.ក.ប នៅពេលធ្វើការត្រួតពិនិត្យឡើងវិញ នូវសម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្នុងចំណុច ១០ ខាងក្រោមនេះ។

១០. សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវតែមកបង្ហាញខ្លួនតាមការកោះអញ្ជើញ របស់ប្រធាន គ.ក.ប និងត្រូវធានាថានឹងមានវត្តមានក្នុងការបំពេញការងារ នៅថ្ងៃបោះឆ្នោត។

- មុនថ្ងៃបោះឆ្នោត ២៤ (ម្ភៃបួន) ម៉ោង ប្រធាន គ.ក.ប ត្រូវប្រជុំ មន្ត្រីទាំងអស់ ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យ បោះឆ្នោត និងពិនិត្យសម្ភារ បរិក្ខារបម្រើឱ្យការបោះឆ្នោត។ ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួស ដោយមន្ត្រីថ្មី ដែលជ្រើសតាំងឡើងតាមការសម្រេចរបស់ គឃ.សប ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

- ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប មិនអាចបំពេញ ការងារក្នុងថ្ងៃបោះឆ្នោតបាន ប្រធាន គ.ក.ប ត្រូវតែជូនដំណឹង ដល់ គឃ.សបដាបន្ទាន់ដើម្បីដាក់ជំនួស។
- ប្រសិនបើប្រធាន គ.ក.ប មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធាន គ.ក.ប ត្រូវចូលកាន់តំណែងប្រធាន គ.ក.ប ហើយសមាជិកទី១ ចូលកាន់តំណែងអនុប្រធាន គ.ក.ប ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋដែលបានដាក់ ពាក្យសម្ភាសន៍ ត្រូវចូលកាន់តំណែងជួសសមាជិកទី១។
- ប្រសិនបើអនុប្រធាន គ.ក.ប មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី១ ជាអនុប្រធាន គ.ក.ប ហើយអ្នក ដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាសមាជិកទី១។
- ប្រសិនបើលេខាធិការមិនអាចមកធ្វើការបាន ត្រូវតែងតាំង សមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែងជាសមាជិកទី១។
- សមាសភាពទាំងអស់នៃ គ.ក.ប រួមទាំងអ្នកដែលទើបតែ ជ្រើសរើសថ្មី ត្រូវរួមគ្នាសិក្សាឡើងវិញនូវនីតិវិធីនៃការបោះឆ្នោត និងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។
- អ្នកតែងតាំងថ្មីទាំងអស់ត្រូវតែបានទទួលការបណ្ដុះបណ្ដាល និងអនុវត្តដូចមានចែងក្នុងចំណុចខាងលើបន្ទាប់នេះ។
- ប្រធាន គ.ក.ប ត្រូវតែជូនដំណឹងជាបន្ទាន់ដល់ គឃ.សប អំពីអ្វីដែលបានអនុវត្តពាក់ព័ន្ធនឹងការដាក់ជួសតំណែងណាមួយ នៃ គ.ក.ប។

១១. បន្ទាប់ពីអនុវត្តចំណុច ១០ ខាងលើនេះរួច គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យ ឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គ.ក.ប បានទទួលហើយ ដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។

- គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារៈ ឯកសារបោះឆ្នោតដោយប្រើតារាងសម្ភារៈ ឯកសារបោះឆ្នោត (ទ.១១១២)។
- ប្រសិនបើសម្ភារៈ ឯកសារបោះឆ្នោតដែលបានទទួលមានចំនួនគ្រប់គ្រាន់ហើយ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខាលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២)។
- ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយ ឬច្រើន ដែលបាន ទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់នៅ លើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ហើយត្រូវធ្វើតារាងត្រួតពិនិត្យនេះ ១ (មួយ) ច្បាប់ ជាបន្ទាន់ទៅ គឃ.សប។
- ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់ទៅនោះជា សម្ភារ ឯកសារសំខាន់សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក ២ (ពីរ) រូបឱ្យធ្វើដំណើរទៅទី ដើម្បីទទួលសម្ភារ ឯកសារថ្មីជំនួស សម្ភារ ស្នាក់ការ គឃ.សប ឯកសារដែលខ្វះ ឬបានបាត់បង់ទៅ លើកលែងតែមានវិទ្យុទាក់ទង ឬទូរសព្ទ ដែលអាចបញ្ជូនព័ត៌មានស្នើសុំ គឃ.សប ដោះស្រាយបញ្ហា ខាងលើបាន។

- ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតខាង លើនេះ គ.ក.ប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារដូច ខាងក្រោម៖
    - ➢ ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នោះ ហើយ គ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលបាន កត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត។
    - ➢ ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជា មានត្រាសម្ងាត់នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រ ជាដាច់ខាត។

១២. សម្ភារឯកសារសំខាន់ៗដែល គ.ក.ប មិនបានទទួលហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន៖

- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់
- ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។
- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។
- ហិបឆ្នោត និងសោឃ្លុំមានលេខ។
- ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃសម្គាល់ថាបាន បោះឆ្នោតហើយ។

១៣. សម្ភារ ឯកសារដទៃទៀត ដែលប្រសិនបើមិនបានផ្តល់ដោយ គឃ.សប នោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង៖

- កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាច ប្រើបិទបាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។
- ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាច ជំនួសទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុជាគំរូ។
- ប៊ិកសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង...។

១៤. នៅពេលដែលសម្ភារ ឯកសារបោះឆ្នោតមានគ្រប់ចំនួនហើយ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ១ (មួយ) ច្បាប់ នៅ មុខការិយាល័យបោះឆ្នោត លើកស្លាកការិយាល័យបោះឆ្នោត និងលេខកូដ ការិយាល័យបោះឆ្នោតនៅនឹងមាត់ច្រកចូលការិយាល័យបោះឆ្នោត។

១៥. បន្ទាប់ពីបានអនុវត្តចំណុច១៤ ខាងលើនេះរួច គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ការិយាល័យបោះឆ្នោតដើម្បីឱ្យប្រាកដថា ទីតាំងការិយាល័យបោះឆ្នោតនោះ អាចដំណើរការបោះឆ្នោតបាន ហើយដែល អាចរៀបចំឱ្យរួចស្រេចនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹកនៃថ្ងៃបោះឆ្នោត។

- គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ឯកភាព គ្នាមួយដោយត្រូវគោរពតាមគោលការណ៍ដូចមានណែនាំក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។

- ប្រសិនបើ គ្មានគ្រឿងសង្ហារិមនៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន គ.ក.ប ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់ នូវគ្រឿងសង្ហារិមចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោតដូចជា តុ កៅអី និងសម្ភារដទៃទៀត ដែលអាចសម្រួលដល់ការងារបោះឆ្នោត។
- ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមការ រក្សាសន្តិសុខទីតាំងការិយាល័យបោះឆ្នោត អាចធ្វើបាន ប្រធាន គ.ក.ប ត្រូវបិទ ការិយាល័យបោះឆ្នោតនោះផង។

១៦. ប្រធាន គ.ក.ប រួមជាមួយសមាជិក គ.ក.ប ត្រូវរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងនោះឱ្យបានហ្មត់ចត់នៅមុនពេលបោះឆ្នោត។

- សម្ភារឯកសារបោះឆ្នោតអាចនឹងរក្សាទុកនៅផ្ទះរបស់ប្រធាន គ.ក.ប ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថាមានសុវត្ថិភាព។
- យ៉ាងហោចណាស់ត្រូវមានសមាជិក គ.ក.ប ៣ (បី) នាក់ គិត ទាំងប្រធាន គ.ក.ប ផងសម្រាកនៅផ្ទះ ឬទីតាំងដែលទទួល រក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព។
- ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ រក្សាទុកសម្ភារ ឯកសារបោះឆ្នោត។

១៧. ប្រធាន គ.ក.ប ត្រូវណាត់ជាមួយសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០ (ប្រាំ សាមសិប) នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូន សម្ភារ ឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត។

១៨. សមាជិកទាំងអស់នៃ គ.ក.ប ត្រូវត្រៀមអាហារសម្រាប់រយៈពេល ១ (មួយ) ថ្ងៃ សម្រាប់ហូបនៅពេលទំនេរដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយ សមស្រប[៤២] ។

### ១.៥ ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត[៤៣]។

## ផ្នែកទី២. ការរាប់សន្លឹកឆ្នោត

### ២.១ ការបិទការបោះឆ្នោត

នៅពេលដែលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី៣ ឱ្យចាត់វិធានការចាំបាច់ដើម្បីការពារ ច្រកចូលការិយាល័យបោះឆ្នោតកុំឱ្យ

[៤២] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៩.៤ ទំព័រ ១៥៣

[៤៣] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ៩.៥ ទំព័រ ១៥៩

អ្នកគ្មានភារកិច្ចចេញចូល ។ ប្រធាន គ.ក.ប ត្រូវប្រកាស បិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មកត្រូវចាត់ចែងការផ្ទៀងផ្ទាត់ចំនួនអ្នក បោះឆ្នោត និងចំនួនសន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ។ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ប្រធានគ.ក.ប ត្រូវចាត់ចែងតាមនីតិវិធីដើម្បីធានាសុវត្ថិភាពហិបឆ្នោត ដែលក្នុងនោះ ៖

- ប្រធាន គ.ក.ប ត្រូវបិទ ភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត ព្រមទាំងបិទក្រដាសស្តើង មួយសន្លឹកដែលមានហត្ថលេខារបស់ប្រធាន គ.ក.ប និង ភ្នាក់ងារគណបក្សនយោបាយពាសពីលើសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនោះផង ។
- ប្រធាន គ.ក.ប ត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោត និង ចាក់សោឃ្លុំមានលេខ នៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរ នៃហិបឆ្នោត រួចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំងពីរនោះ ។
- លេខាធិការត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុនៃការបោះឆ្នោត(ទ.១១០១) នូវពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំងពីរ ។
- ប្រធាន គ.ក.ប ត្រូវចាត់វិធានការការពារហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់សម្រាប់ការរាប់សន្លឹកឆ្នោតនៅនឹងកន្លែងការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចឲ្យធ្វើដូច្នេះដោយ គ.ជ.ប ។
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចថតយក ក្រោយពីការប្រកាស សកម្មភាពនៅការិយាល័យបោះឆ្នោត បិទការបោះឆ្នោតដោយសុំការអនុញ្ញាតពីប្រធាន គ.ក.ប ។បន្ទាប់មក ស្ថិតនៅចំពោះមុខវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិកនៃ គ.ក.ប ឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើសន្លឹកឆ្នោត មិនបានប្រើ និងសន្លឹកឆ្នោតខូច (ប្រសិនបើមាន) ដែលក្នុងនោះលេខាធិការត្រូវរាប់ចំនួនគំនូសសញ្ញាក្នុងកូនប្រអប់ផ្នែកខាងដើមនៅក្នុងបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធាន គ.ក.ប អំពីចំនួនអ្នកបោះឆ្នោត ដែលបានបោះឆ្នោត ។
- អនុប្រធាន គ.ក.ប ត្រូវកំណត់សម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ និងគល់បញ្ជីនៃសន្លឹកឆ្នោតដែលមិនទាន់បានប្រើ រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូចដោយឡែកពីគ្នា ។
- ប្រសិនបើ ក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា នៅមានភាពខុសគ្នា រវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោត ដែលបានបោះឆ្នោត លេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរ នូវចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនៅលើបញ្ជីបោះឆ្នោត ហើយអនុប្រធាន គ.ក.ប ក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញផងដែរនូវចំនួនសន្លឹកឆ្នោតដែលបានប្រើ (រាប់ចំនួនសន្លឹកគល់បញ្ជីនៃ សន្លឹកឆ្នោតដែលបានប្រើ) ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច ។ ប្រសិនបើ ភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រានូវ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ហើយប្រធាន គ.ក.ប ត្រូវបន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត ។

- សមាជិកទី២ ត្រូវចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើ ទាំងអស់ជាមួយនឹងប្រដាប់ចោះ ឬកន្ត្រៃ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ ។
- អនុប្រធាន គ.ក.ប ត្រូវដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ទៅក្នុងស្បោងប្លាស្ទិកតែមួយរួចបិទឱ្យជិត ។

ប្រធាន គ.ក.ប ត្រូវធានាថា លេខាធិការបានកត់ត្រាជាមុននូវលេខសោឃ្លុំដែលនឹងត្រូវប្រើចាក់ឃ្លុំមាត់ស្បោង "ខ" ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងបោះត្រាសម្ងាត់ នៅជ្រុងខាងស្តាំ ប៉ែកខាងលើនៃកំណត់ហេតុនេះ ។ កំណត់ហេតុនៃការ បោះឆ្នោត (ទ.១១០១) ចំនួន ២ (ពីរ) ច្បាប់ ដែលលេខាធិការបានបំពេញ រួចត្រូវចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.ប និងបោះត្រា គ.ក.ប ។

- ប្រធាន គ.ក.ប ត្រូវដាក់បង្ហាញកំណត់ហេតុដូចមានចែងក្នុង ចំណុចខាងលើបន្ទាប់ នៅចំពោះមុខភ្នាក់ងារគណបក្ស នយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។
- ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ជាសាក្សីលើកំណត់ហេតុខាងលើនេះ ។
- ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុ នេះបានទេ ។

ប្រធាន គ.ក.ប ត្រូវរៀបចំកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដែលបានចុះហត្ថលេខារួច ដូចមានចែងក្រោមចំណុចខាងលើ ដូចខាងក្រោមៈ

- ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដៃ ដែលមាន កាខ្នងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រា សំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ .១១០២) ផ្ញើជូន គ.ជ.ប"។
- ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដៃលមាន កាខ្នងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ .១១០១) តារាងកត់ត្រា សំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គឃ.សប" ។
- ឯកសារបោះឆ្នោតពាកព័ន្ធ បន្ទាប់មកប្រធាន គ.ក.ប ទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់ សុវត្ថិភាព "ក" ដែលមានបោះពុម្ពសម្គាល់ថា "ការិយាល័យបោះឆ្នោតលេខ" នូវៈ
    - ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។
    - ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត។
    - ស្រោមសំបុត្រដាក់ "សន្លឹកឆ្នោតខូច" (ប្រសិនបើមាន) ។
    - ស្បោងប្លាស្ទិកដាក់ "សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជី
    - ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។
    - ស្រោមសំបុត្រដាក់ "សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត" (ប្រសិនបើមាន) ។
    - ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិន បើមាន) ។

ប្រធាន គ.ក.ប ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ថា រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព "ក" ។ ប្រធាន គ.ក.ប ត្រូវធានាថា ឡើយកញ្ចប់សុវត្ថិភាព "ក" នៅពេលនេះ មិនទាន់ត្រូវបិទភ្ជិតឡើយហើយនឹងត្រូវ បិទភ្ជិតដោយសុវត្ថិភាពបម្រុងស្រាប់លុះណាតែ គ.ក.រ បានបញ្ចប់ការ រាប់សន្លឹកឆ្នោត និងបានដាក់តារាងកត់ត្រាសំឡេងឆ្នោត(ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងសម្ភារ ឯកសារបោះឆ្នោត ផ្សេងទៀតទៅក្នុងកញ្ចប់សុវត្ថិភាព "ក" ពាក់ព័ន្ធរួចរាល់សិន ។

ប្រធាន គ.ក.ប ត្រូវធានាថា កញ្ចប់សុវត្ថិភាព "ក" និងស្រោមសំបុត្រ ត្រូវបានបំពេញលេខកូដការិយាល័យពាក់ព័ន្ធយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ ។

ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិក គ.ក.ប ឱ្យរៀបចំទុកដាក់សម្ភារ ឯកសារ ថ្កែលនៅសល់ក្នុងកេសស័ង្កសី និងវេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដោយឡែក ។ ទន្ទឹមនឹងនេះ ត្រូវរុះរើបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតទាំង ២ (ពីរ) រួច ច្រកទៅក្នុងការុងនីឡុងដែលបានប្រើសម្រាប់ដាក់បន្ទប់សម្ងាត់ ដូចនៅពេលប្រគល់ជូន គ.ក.ប នាពេលដំបូង[៤៤]។

## ២.២. ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតាមការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ លើកលែងតែការិយាល័យបោះឆ្នោតណាមួយដែលមានសេចក្តីសម្រេចផ្សេងពីនេះដោយ គ.ជ.ប។ គ.ក.ប ក្លាយជា គ.ក.រ នៅពេលរាប់សន្លឹកឆ្នោត។

ការរាប់សន្លឹកឆ្នោតត្រូវធ្វើបន្ទាប់ពីបិទការបោះឆ្នោត និងការធ្វើកំណត់ហេតុនៃការបោះឆ្នោត ចប់រួចរាល់នាល្ងាចថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២។

ការផ្ទៀងផ្ទាត់ និងការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតែ ១ (មួយ) កន្លែង សម្រាប់ការិយាល័យ បោះឆ្នោត ១ ឱ្យចប់ចុងចប់ដើម ដោយពុំត្រូវឈប់សម្រាកឡើយ ហើយធ្វើចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន (ទ.១១១៥ )នៅមុន ពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត ហើយអាចផ្លាស់ប្តូរភ្នាក់ងារបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យចប់ចុងចប់ដើម។

ប្រធាន គ.ក.រ ត្រូវចាត់ចែងរៀបចំតាមគំរូប្លង់សម្រាប់ការរាប់សន្លឹកឆ្នោត និងមានវិធាន ការពារសន្តិសុខក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

[៤៤] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ១០.១ ទំព័រ ១៨១

**១. ការចាត់ចែងរៀបចំបន្ទប់រាប់សន្លឹកឆ្នោត**

❖ ប្រធាន គ.ក.រ មានតួនាទីរៀបចំចាត់ចែងដូចខាងក្រោមៈ

- ត្រូវចាត់ចែងរៀបចំតាមប្លង់ការិយាល័យរាប់សន្លឹកឆ្នោត និងទុកដាក់សម្ភារ ឯកសារដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព។
- ត្រូវរៀបចំតុធំ១ ឬតុតូចច្រើនផ្គុំគ្នា និងកៅអីចំនួន ៤ (បួន) សម្រាប់សមាជិក គ.ក.រ ដាក់ចំកណ្តាលបន្ទប់ដែលអាចឱ្យភ្នាក់ងារគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ដើរចុះឡើងជុំវិញតុ ដើម្បីសង្កេតមើលសកម្មភាព ទាំងឡាយនៃការរាប់សន្លឹកឆ្នោត។
- ត្រូវបិទផ្ទាំងក្រដាសធំ ១ សន្លឹក ភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀន សម្រាប់កត់ត្រា សំឡេងឆ្នោត។
- ត្រូវលើកហិបឆ្នោតដាក់ចំកណ្តាលតុ និងដាក់កញ្ចប់សុវត្ថិភាព "ក" រាល់ សម្ភារ ឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ច ប្រតិបត្តិការរាប់សន្លឹកឆ្នោត មកដាក់នៅលើតុត្រង់កន្លែងខ្លួនអង្គុយ។
- ត្រូវត្រៀមភ្លើងសម្រាប់បំភ្លឺក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់យប់។
- ត្រូវអង្គុយចុងតុម្ខាងទល់មុខលេខាធិការ។ អនុប្រធាន និងសមាជិកទី១ អង្គុយអមសងខាងតុទល់មុខគ្នា។
- ត្រូវចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួច ដែលបើកចំហ កុំឱ្យមានអ្នកចេញ ចូលមើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោតដែលមិនត្រូវបានប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើល ថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

**២. វិធានការចំពោះករណីអ្នកធ្វើសកម្មភាពមិនប្រក្រតី**

❖ ប្រធាន គ.ក.រ មានវិធានការដូចខាងក្រោមៈ

- ត្រូវព្រមានផ្ទាល់ចំពោះការធ្វើសកម្មភាពលើកទី១។
- ត្រូវបណ្តេញចេញពី ការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ឃ.ស ចំពោះការធ្វើសកម្មភាពលើកទី២។
- ត្រូវចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍នោះក្នុងកំណត់ហេតុមួយ ដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត។
- ត្រូវបញ្ជូនកំណត់ហេតុនេះជូន គឃ.សប ជាបន្ទាន់។
    - នៅពេលទទួលបានកំណត់ហេតុនេះ គឃ.សប ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។
    - ប្រសិនបើមានភស្តុតាងបញ្ជាក់ថាបានរំលោភពិតប្រាកដមែន គឃ.សប ត្រូវបញ្ជូនករណីនេះទៅ គជ.ឧប ដើម្បី គជ.ឧប ចាត់វិធានការតាមផ្លូវច្បាប់[៤៥]។

## ២.៣. សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ

[៤៥] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ១០.២ ទំព័រ ១៨៥

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេស ប្រធាន អនុប្រធាន គ.ក.រ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈ នៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ។

**ក. សន្លឹកឆ្នោតបានការ**

- ជាសន្លឹកឆ្នោត គ.ក.ប ចែកឱ្យជាសន្លឹកឆ្នោតមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង។
- សន្លឹកឆ្នោតមានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ

**ខ. សន្លឹកឆ្នោតមិនបានការ**

សន្លឹកឆ្នោតមិនបានការត្រូវចាត់ទុកជាមោឃៈមាន ប្រាំប្រភេទដូចខាងក្រោម៖

១. សន្លឹកឆ្នោតដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ៖

- សន្លឹកឆ្នោតមានខ្នាតតូច ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប។
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប។
- សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបាន ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ។
- សន្លឹកឆ្នោតមានឈ្មោះគណបក្សលើសពីចំនួនគណបក្សនយោបាយឈរ ឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ។
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ។
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិន ត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បាន បោះពុម្ពផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ។

២. សន្លឹកឆ្នោតដែលគ្មានគំនូស ឬមានគំនូសតែ គ.ក.រ ពុំអាចសន្និដ្ឋានបានថាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ៖

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)។
- សន្លឹកឆ្នោតមានគំនូសក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយ ដោយគូសហួសចូលទៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយ មួយទៀត។
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយ លើសពីមួយគណបក្សនយោបាយ។

- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់បួនជ្រុង ទ្រវែងនៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះ មាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ។

៣. សន្លឹកឆ្នោតមានសញ្ញា ឬរូបភាពដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត៖

- សន្លឹកឆ្នោតដែលមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃ គណបក្សនយោបាយណាមួយ ឬ/និងលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត។
- សន្លឹកឆ្នោតមានផ្ដិតស្នាមម្រាមដៃ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួន ជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាង មុខ ឬខាងខ្នងនៃសន្លឹកឆ្នោត។
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាស មានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នៅត្រង់ប្រអប់បួនជ្រុងទ្រវែងនៃ គណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃ សន្លឹកឆ្នោត។
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយសន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេ ស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត។

៤. សន្លឹកឆ្នោតដែលមានរហែក ឬប្រឡាក់ខូច៖

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែងនៃ គណបក្សនយោបាយណាមួយសន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង។
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងខាងខ្នង ដែលមិនអាចមើលឃើញនូវរូបសញ្ញា និងអក្សរដែលបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយ ណាមួយ។

៥. សន្លឹកឆ្នោតដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការ៖

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃ ការិយាល័យបោះឆ្នោតពាក់ព័ន្ធ[៤៦]។

## ផ្នែកទី៣. ការប្រកាសលទ្ធផលបោះឆ្នោត

### ៣.១. លទ្ធផលបណ្ដោះអាសន្ន

#### ៣.១.១. កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកលទ្ធផលបណ្ដោះអាន្ននៃការបោះឆ្នោត

[៤៦] បទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ១០.៣ ទំព័រ ១៩៧

បន្ទាប់ពីបានទទួលកញ្ចប់ "គ ពិសេស" និងស្បោង "គ" នៃឃុំ សង្កាត់មួយចំនួនហើយ គជ.ខប ត្រូវចាត់វិធានការជាបណ្តើរៗឱ្យក្រុមត្រួតពិនិត្យលទ្ធផលឱ្យធ្វើការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុកតាមករណីនីមួយៗដោយឡែកពីគ្នា សង្កាត់គ្មានពាក្យបណ្តឹង ទាំងឃុំ សង្កាត់មានពាក្យបណ្តឹងឱ្យរួចរាល់ឆាប់រហ័សតាមដែលអាច ធ្វើបាន និងមិនត្រូវឱ្យហួសរយៈពេល ៥ (ប្រាំ) ថ្ងៃឡើយដោយគិតចាប់ពីថ្ងៃបានទទួលកញ្ចប់ "គ"ពិសេស" និងស្បោង "គ" នៃឃុំ សង្កាត់ពាក់ព័ន្ធ។

ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្តឹង ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ចំណុះ រាជធានី ខេត្តនៅមជ្ឈមណ្ឌលត្រួតពិនិត្យនៃ គជ.ខប។

- ភ្នាក់ងារគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ ប្រចាំការ តាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យ មានតំណាងពេញសិទ្ធិ និងតំណាងបម្រុងរបស់ខ្លួនតាមចំនួន ដែល គជ.ខប បានកំណត់ដែលអាចចូលរួមគ្រប់គ្រាន់ល្មមក្នុង ការសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល នៃ គជ.ខប ព្រមទាំងអ្នកសារព័ត៌មានផងដែរ។
- ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលត្រូវ ចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យ លទ្ធផលនៃ គជ.ខប នីមួយៗ អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យ បំពេញភារកិច្ចជំនួសខ្លួន។
- ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញ នូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យលទ្ធផលបណ្តោះ អាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត។
- ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាងអាចថតយករូបភាពនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាប៉ុន្តែមិនត្រូវបង្កការអុកឡុក ឬរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យ រាំងស្ទះដល់ដំណើរការនេះឡើយ។

កិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ជាពិសេសចំពោះឃុំ សង្កាត់មាន ពាក្យបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យក្រុមត្រួតពិនិត្យ លទ្ធផលបើកកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

គជ.ខប ត្រូវចាត់ចែងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃ ការបោះឆ្នោតតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត នៅបន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើននៃមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផល។ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ពីរ ឬច្រើនក្រុម អាចបំពេញការងារនៅតាមតុរៀងខ្លួន ក្នុងបន្ទប់តែមួយ ឬនៅតាមបន្ទប់ដោយឡែកពីគ្នា ដោយយោងតាមលទ្ធភាពជាក់ស្តែងរបស់រាជធានី ខេត្ត ។ ក្រុមត្រួតពិនិត្យលទ្ធ

ផលនីមួយៗ ត្រូវរៀបចំគំរូប្លង់បន្ទប់តាមលំនាំបន្ទប់រាប់សន្លឹកឆ្នោត និងត្រូវមានសម្ភារ ឯកសារ និងទម្រង់បែបបទគ្រប់គ្រាន់សម្រាប់បំពេញការងារ ។

- ក្នុងការត្រួតពិនិត្យលទ្ធផលខាងលើនេះ ប្រធានក្រុមត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់ មុខប្រធានក្រុម ហើយឱ្យអនុប្រធានក្រុម និងជំនួយការអង្គុយ នៅអមសងខាងតុទល់មុខគ្នា។
- ប្រធានក្រុមត្រូវត្រៀមនៅក្បែរខ្លួនគាត់នូវពាក្យបណ្ដឹង (ទ.១២០២) សម្រាប់ប្រគល់ជូនភ្នាក់ងារគណបក្សនយោបាយ ឬអ្នកប្ដឹង ដើម្បីបំពេញពាក្យបណ្ដឹង ប្រសិនបើមានការស្នើសុំ និងរាល់ ទម្រង់បែបបទចាំបាច់ផ្សេងទៀតសម្រាប់ប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ។
- ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនេះ។

គធ.ខប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលបណ្ដោះ អាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ដោយឡែកពីគ្នា និងតាមលំដាប់លំដោយនៃករណីជាក់ស្ដែងនីមួយៗ។ ប្រសិនបើលក្ខខណ្ឌតម្រូវ ក្រុមត្រួតពិនិត្យលទ្ធផលអាចធ្វើការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ពាក់ព័ន្ធដោយគួបផ្សំការអនុវត្តនីតិវិធីសម្រាប់ករណីលើសពីមួយស្របពេលជាមួយគ្នា[៤៧] ។

### ៣.១.២. ការពិនិត្យ និងចុះហត្ថលេខាលើលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបឃ.ស

បន្ទាប់ពីបានត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ កំណត់ ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ស្រង់ឈ្មោះបេក្ខជនដែលត្រូវជាប់ឆ្នោតជាសមាជិក កបឃ.ស ត្រូវជាប់ឆ្នោតជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រងនៃឃុំ សង្កាត់នីមួយៗចំណុះរាជធានី ខេត្ត រួចរាល់ហើយ ប្រធាន គធ.ខប ត្រូវធានាថា តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត តាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) និងលទ្ធផលបណ្ដោះអាសន្ននៃការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ត្រូវតែបានបោះពុម្ព ចុះហត្ថលេខា និងកាលបរិច្ឆេទ រួចបញ្ជូនដោយវេចខ្ចប់អមជាមួយនូវសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប ដើម្បីពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ ។

តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ៣ (បី) ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួចហើយ ត្រូវចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទដោយប្រធានអនុគណៈកម្មការបច្ចេកទេស និង ប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះភ្នាក់ងារគណបក្សនយោបាយ

[៤៧] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ១១.៥ ទំព័រ ២៤៨

ពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ ប្រធាន គធ.ឌប ត្រូវចាត់ចែង និងប្រើប្រាស់តារាងលទ្ធផលខាងលើនេះ ដូចខាងក្រោម ៖

- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ក្នុងស្រោម សំបុត្របោះពុម្ពស្រាប់ដែលមានកាខ្នងថា "តារាងលទ្ធផល បណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត... ផ្ញើជូន គ.ជ.ប"
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ចំនួន ៣ (បី) ច្បាប់ ដែលបានបោះពុម្ពរួចហើយ ត្រូវចុះហត្ថលេខាបោះត្រា (ទ.១១០៥ធឌ) និងកាលបរិច្ឆេទដោយ ប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ឌប រួចដាក់បង្ហាញ ប្រធានភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ ប្រធាន គធ.ឌប ត្រូវចាត់ចែង និងប្រើប្រាស់ក្រដាសលទ្ធផលខាងលើនេះ ដូចខាងក្រោម៖

- បិទផ្សាយ ១ (មួយ) ច្បាប់ នៅ លគធ.ឌប ។
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្រ បោះពុម្ពស្រាប់ ដែលមានកាខ្នងថា "ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់លេខ... (បំពេញលេខកូដ ឃុំ សង្កាត់ពាក់ព័ន្ធ) ផ្ញើជូន គ.ជ.ប" ។
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ចំនួន ៣ (បី) ច្បាប់ ដែលបានបំពេញរួចហើយ ត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទដោយ ប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ឌប រួចដាក់បង្ហាញ ចំពោះភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ ប្រធាន គធ.ឌប ត្រូវចាត់ចែង និងប្រើប្រាស់លទ្ធផលខាងលើនេះ ដូចខាងក្រោម ៖

- បិទផ្សាយ ១ (មួយ) ច្បាប់ នៅ លគធ.ឌប ។
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោម សំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្នងថា "លទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លេខ... (បំពេញ លេខកូដ ឃុំ សង្កាត់ពាក់ព័ន្ធ) ផ្ញើជូនគ.ជ.ប ។
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ប្រធាន គធ.ឌប ត្រូវធានាថារូបភាព និងទិន្នន័យនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តារាងកត់ត្រា សំឡេងឆ្នោត (ទ.១១០៨) តារាងបូកសរុបលទ្ធផលបណ្តោះអាសន្នក្នុងឃុំ សង្កាត់ (ទ.១១០៩) កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុង ឃុំ សង្កាត់ (ទ.១១១៦គព) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ឌប (ទ.១១០៥ធឌ) តារាងលទ្ធផល បណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ដែលមានក្នុងប្រព័ន្ធកុំព្យូទ័រ ត្រូវបានរក្សាទុកក្នុង

ហ្លាស់ (USB Drive) មួយ ចងដោយលេខកូដសម្ងាត់ និងត្រូវដាក់ក្នុងស្រោមសំបុត្របញ្ជូនមក គ.ជ.ប ហើយ ទិន្នន័យទាំងអស់នេះ ក៏ត្រូវផ្ញើមក គ.ជ.ប តាមអ៊ីនធឺណិតផងដែរ ។

ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធអាចស្នើសុំថតចម្លងក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) ឬលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ (ទ.១១១១)[៤៨] ។

### ៣.១.៣. ការបង្កើតមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការ បោះឆ្នោតតាមឃុំ សង្កាត់ កំណត់ចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបឃ.ស និងកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតដែល ត្រូវទទួលតំណែងជាប្រធាន កបឃ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង តាមប្រមាណវិធី ដោយដៃ និងតាមប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត កំណត់ដោយ គ.ជ.ប ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យ សម្រេចជាផ្លូវការ ។

មជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត តាមឃុំ សង្កាត់ អាចមានទីតាំងនៅ លគធ.ខប ឬនៅអគារមួយផ្សេង ឬផ្ទែកមួយ ដែលមានទំហំទូលាយល្មមអាចរៀបចំឱ្យមានកន្លែងបម្រុងដូចខាងក្រោម ៖

- កន្លែងសម្រាប់ទទួលស្បោង "គ" និងកញ្ចប់ "គ ពិសេស" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ពីគ្រប់ឃុំ សង្កាត់ ចំណុះ រាជធានី ខេត្តពាក់ព័ន្ធដែលស្ថិតនៅក្បែរផ្លូវចូល។
- បន្ទប់មួយទូលាយល្មមដែលអាចស្តុកស្បោង "គ" និងកញ្ចប់ "គ ពិសេស" ដាច់ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ និងមាន សរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង ។
- បន្ទប់មួយដោយឡែកដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ផ្សេងទៀត ដែល គឃ.សប បានប្រគល់ឱ្យ ។
- បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ដែលត្រូវមានតុ និង កៅអីគ្រប់គ្រាន់សម្រាប់ប្រើក្នុងពេលត្រួតពិនិត្យលទ្ធផល បណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ហើយដែល អាចទទួលបានទាំងក្រុមត្រួតពិនិត្យលទ្ធផលរបស់ គធ.ខប ទាំងភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្ដឹងពាក់ព័ន្ធ ឬតំណាង ។
- បន្ទប់ស្អាតតូចមួយ (ប្រសិនបើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារ កុំព្យូទ័រ ដែលមានភ្ជាប់អ៊ីនធឺណិតមានទិន្នន័យគ្រប់គ្រាន់ពាក់ព័ន្ធ នឹងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមឃុំ

[៤៨] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ១១.១០ ទំព័រ ២៧១

សង្កាត់ក្នុងរាជធានី ខេត្ត និងមានបំពាក់កម្មវិធី ប្រតិបត្តិការបែងចែកអាសនៈ ដែលរៀបចំ និងផ្តល់ជូនដោយ គ.ជ.ប ។

គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលរបស់ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ។ ទ្វារ និងបង្អួចទាំងអស់ត្រូវបិទ និងចាក់សោយ៉ាងត្រឹមត្រូវ នៅពេលផុតម៉ោង ធ្វើការងារ ។ នៅក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការ បោះឆ្នោតតាមឃុំ សង្កាត់ គធ.ខប ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ទទួលបន្ទុកសណ្តាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល និងមានមន្ត្រីម្នាក់ប្រចាំការនៅមាត់ទ្វារចេញ ចូលដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ.ខប ។

គធ.ខប ត្រូវតែរៀបចំឱ្យមានបរិវេណសន្តិសុខមួយនៅអគារមជ្ឈមណ្ឌលនៃគធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ដោយនៅខ្សែក្រវាត់ខាងក្រៅ ត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការ ឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់កម្លាំងការពារ និងទទួលបន្ទុកការពារនៅខ្សែក្រវាត់ខាងក្នុងត្រូវចាត់កម្លាំងសន្តិសុខផ្ទាល់របស់ គធ.ខប ដើម្បីការពារ[៤៩]។

## ៣.២. លទ្ធផលផ្លូវការ

### ៣.២.១. ការរៀបចំ និងផ្សព្វផ្សាយសេចក្តីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីនៃការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅ គ.ជ.ប ត្រូវធានាថា ៖

- ផ្អែកតាមរាល់សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ គ.ជ.ប បានរៀបចំ និងចាត់ចែងការបោះឆ្នោត សាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យទាំងអស់នៃឃុំ សង្កាត់ពាក់ព័ន្ធ ។
- ផ្អែកតាមរាល់សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានយល់ព្រមទទួលយក លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ហើយដែលត្រូវបានក្រុមកំណត់ បែងចែកអាសនៈ រៀបចំសំណុំឯកសារពាក់ព័ន្ធដាក់ជូន គ.ជ.ប តាមរយៈ អគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យសម្រេច ហើយប្រធាន គ.ជ.ប បានចុះហត្ថលេខាបោះត្រា និង ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ។ ប្រធាន គ.ជ.ប ត្រូវចាត់ចែង និងប្រើប្រាស់សេចក្តីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ដូចខាងក្រោម ៖
    - ផ្ញើជូននាយករដ្ឋមន្ត្រី ១ (មួយ) ច្បាប់ ។
    - ផ្ញើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់ ។
    - ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ដើម្បីបិទផ្សាយនៅលគធ.ខប ។

[៤៩] បទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២) ប្រការ ១១.២ ទំព័រ ២៣៦

- ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ដើម្បីបិទផ្សាយនៅ ទីស្នាក់ការ គឃ.សប ។
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ចាត់ចែងផ្សព្វផ្សាយជាសាធារណៈ ។

ផ្អែកតាមរាល់សេចក្ដីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវបោះឆ្នោតសាជាថ្មី ប្រធាន គ.ជ.ប បានចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទលើសេចក្ដីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ពាក់ព័ន្ធ និងបានចាត់ចែងប្រើប្រាស់តាមការកំណត់[៥០]។

[៥០] បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ (២០២២) ប្រការ ១១.២០ ទំព័រ ៣១៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបជារួមមក ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការជ្រើសរើសអ្នកតំណាង ឬគណបក្សណាមួយក្នុងចំណោមគណបក្សទាំងឡាយដែលចូលរួមប្រកួតប្រជែងគ្នាធ្វើជាអ្នកដឹកនាំឃុំ សង្កាត់របស់ខ្លួន។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជា បានរៀបចំឡើងដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋប្រើសិទ្ធិអំណាចរបស់ខ្លួនជ្រើសរើសមេឃុំ ឬចៅសង្កាត់ ព្រមទាំងក្រុមប្រឹក្សាឃុំ ឬសង្កាត់ ដែលជាក្បាលម៉ាស៊ីនដឹកនាំនៅតាមឃុំ-សង្កាត់ ដែលពួកគេកំពុងរស់នៅ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ អនុវត្តន៍តាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងមានលក្ខណៈជាសកល ដោយត្រូវធ្វើឡើងរៀងរាល់ ៥(ប្រាំ) ឆ្នាំម្តង ហើយត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នាទូទាំងប្រទេស។ កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើររបស់មន្ត្រីក្រសួងមហាផ្ទៃ ហើយនាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេលយ៉ាងតិច ០៩ (ប្រាំបួន) ខែ យ៉ាងតិចមុនថ្ងៃបោះឆ្នោត។ ការបោះឆ្នោតត្រូវធ្វើថ្ងៃអាទិត្យ តែមួយថ្ងៃប៉ុណ្ណោះ។ ការបោះឆ្នោតជាសិទ្ធិនយោបាយ និងជាការទទួលខុសត្រូវដ៏សំខាន់របស់ប្រជាពលរដ្ឋ គ្រប់រូបក្នុងការអនុវត្តន៍សិទ្ធិនៃការគ្រប់គ្រងអំណាចដោយខ្លួនឯងតាមរយៈការបោះឆ្នោត ព្រោះនៅក្នុងសង្គមប្រកាន់ប្រជាធិបតេយ្យ ប្រជាពលរដ្ឋជាម្ចាស់ប្រទេស ជាម្ចាស់សិទ្ធិអំណាច ជាអ្នកបោះឆ្នោតជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្ត និងតាមឆន្ទៈរបស់ខ្លួន។

ការបោះឆ្នោតគឺជាពេលវេលាមួយដែលប្រជាពលរដ្ឋគ្រប់រូបបានសំដែងឆន្ទៈរបស់ខ្លួនដើម្បីបោះឆ្នោតជ្រើសរើសបេក្ខជនដែលខ្លួនពេញចិត្តឱ្យធ្វើជាអ្នកតំណាងរបស់ខ្លួនដោយគិតទៅលើសមត្ថភាពការងារទស្សនវិជ្ជាក្នុងការដោះស្រាយបញ្ហា និងការប្តេជ្ញាចិត្តបម្រើសុខសុមាភាពរបស់ប្រជាជនការខិតខំកសាងប្រទេសជាតិទាំងមូល។ ដើម្បីអនុវត្តន៍របបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្សអោយបានជោគជ័យនោះ ការរៀបចំដំណើរការបោះឆ្នោត ត្រូវតែប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព គ្មានការបំភិតបំភ័យ គ្មានការគំរាមគំហែង គ្មានការទិញទឹកចិត្ត និងប្រព្រឹត្តទៅដោយទៀតទាត់ពេលវេលា។ ដើម្បីធានាដល់ការដំណើរការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានសមត្ថកិច្ចគ្រប់គ្រងរាល់ការបោះឆ្នោត បានអនុម័តគោលការណ៍មួយចំនួនដែលស្របតាមច្បាប់បោះឆ្នោត សម្រាប់ណែនាំដល់គណបក្សនយោបាយ បេក្ខជនឈរឈ្មោះអោយគេបោះឆ្នោត និងអ្នកបោះឆ្នោតអោយប្រតិបត្តិតាម និងគួរចៀសវាងអ្វីខ្លះដែលផ្ទុយនឹងច្បាប់បានកំណត់។ មធ្យោបាយមួយទៀតដែលអាចធានាអោយការបោះឆ្នោតប្រព្រឹត្តទៅបានដោយត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព គឺត្រូវមានអ្នកសង្កេតការណ៍អព្យាក្រឹត្យមិនលំអៀង និងមិនជ្រៀតជ្រែកទៅក្នុងការដឹកនាំ និងការរៀបចំការបោះឆ្នោតដោយប្រការណាមួយឡើយ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កន្លងមកឃើញថា ការបោះឆ្នោតកន្លងមកបានដំណើរការល្អហើយ ប៉ុន្តែក៏មានចំណុចខ្លះនៅមិនទាន់បានអនុវត្តន៍បានឥតខ្ចោះនៅឡើយទេដូច្នេះ ក្នុងនាមនាងខ្ញុំទាំងពីរជានិស្សិតកំពុងសិក្សាស្រាវជ្រាវអំពីប្រធានបទនេះ នាងខ្ញុំទាំងពីរសុំការអនុញ្ញាតធ្វើការបញ្ចេញមតិយោបល់ដូចខាងក្រោមះ

- គួរធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនប្រកបដោយឯករាជ្យ មិនពុករលួយ បក្សពួកនិយម។
- ធ្វើការចំណាយថវិកាឱ្យចំគោលដៅ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។
- អនុវត្តច្បាប់ដោយតម្លាភាព ចំពោះគ្រប់ភាគីគណបក្សនយោបាយទាំងអស់ ដោយពុំមានភាពរុញរាជាពិសេសនាយកដ្ឋានច្បាប់របស់ខ្លួនតែម្តង។
- រាល់ការឃោសនាអំពីការបោះឆ្នោតត្រូវចាត់កងកម្លាំងចាំការពារប្រជាពលរដ្ឋដែលបានចូលរួមការឃោសនាការបោះឆ្នោត ជៀសវាងកុំឱ្យមានជនដែលមិនពេញចិត្តគណបក្សណាមួយធ្វើសកម្មភាពមិនប្រក្រតីដែលប៉ះពាល់ដល់អ្នកចូលរួម។
- ពង្រឹងសន្តិសុខការពារអំឡុងពេលបោះឆ្នោតដើម្បីការពារកុំឱ្យមានការក្លែងបន្លំអត្តសញ្ញាណអ្នកបោះឆ្នោត។
- ត្រួតពិនិត្យឱ្យបានច្បាស់លាស់នូវឯកសារផ្លូវការរបស់ប្រជាពលរដ្ឋដែលមានឈ្មោះមុនពេលចូលបោះឆ្នោត។
- ផ្តល់អាទិភាពខ្ពស់ដល់អ្នកបោះឆ្នោតដូចជាមនុស្សចាស់ ស្ត្រីមានផ្ទៃពោះ ជនពិការ ដើម្បីសម្រួលកុំឱ្យពួកគាត់រងចាំយូរ។
- ពង្រឹងចាត់ឱ្យមានក្រុមគ្រូពេទ្យចាំជួយសង្គ្រោះក្នុងករណីមានអ្នកដួលសន្លប់ ខ្យល់គ ឬដោយប្រការណាមួយ។
- ការបោះឆ្នោតត្រូវមានភាពសុក្រឹត្យ តម្លាភាព យុត្តិធម៌ កុំឱ្យមានការស៊ីសំណូក ស៊ូកប៉ាន់ដល់គណបក្សណាមួយដើម្បីឈ្នះឆ្នោត។
- អ្នកអង្កេតការនៅក្នុងការិយាល័យបោះឆ្នោតត្រូវត្រួតពិនិត្យរាល់សកម្មភាពទាំងអស់របស់អ្នកបោះឆ្នោតពីមួយជំហានទៅមួយជំហាន។
- ណែនាំដល់ប្រជាពលរដ្ឋអំពីច្បាប់ ឬអ្វីដែលពួកគាត់ត្រូវធ្វើឱ្យបានត្រឹមត្រូវដូចជា មានសិទ្ធិបោះឆ្នោតតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់ អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តែមួយប៉ុណ្ណោះ។
- ប្រសិនបើអ្នកដឹកនាំឃុំ សង្កាត់ណាមួយមិនបានល្អដែលធ្វើឱ្យប្រជាពលរដ្ឋមិនពេញចិត្តត្រូវផ្លាស់ប្តូរអ្នកដឹកនាំដោយសន្តិវិធី គ្មានការប្រើអំពើហិង្សា។
- អ្នកដឹកនាំមានការទទួលខុសត្រូវផ្ទាល់ ចំពោះមុខប្រជាពលរដ្ឋ។
- លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរ។
- អនុវត្តន៍សិទ្ធិនយោបាយ និងលទ្ធិប្រជាធិបតេយ្យ។
- ធានាការពារការប្រតិបត្តិសិទ្ធិសេរីទាំងអស់របស់បុគ្គលគ្រប់ៗរូបអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

# ឯកសារយោង

# ឯកសារយោង

## ១. សៀវភៅ/ទស្សនាវដ្តី

- សៀវភៅបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- សៀវភៅរបាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២
- សៀវភៅណែនាំគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- សៀវភៅណែនាំគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

## ២. លិខិតបទដ្ឋានគតិយុត្តជាតិ

- ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ "ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មធិការជាតិរៀបចំការបោះឆ្នោត"
- ព្រះរាជក្រមលេខ នស/ រកម/ ០៣១៥/ ០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ "ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ"
- ព្រះរាជក្រមលេខ នស/ រកម/ ១០១៧/ ០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ "ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់"
- ព្រះរាជក្រមលេខ នស/ រកម/ ១២១៥/ ០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ "ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់"
- ព្រះរាជក្រមលេខ នស/រកម/ ០៣០១/ ០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ "ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- មាត្រា ១៤៥.ថ្មី(មួយ) និង មាត្រា ១៤៦.ថ្មី(មួយ) នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

## ៣. គេហទំព័រសំខាន់ៗ

- គេហទំព័រ https://www.nec.gov.kh/khmer/content/5700 ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២
- គេហទំព័រ https://www.nec.gov.kh/khmer/content/5670 ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.nec.gov.kh/khmer/category/387ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២
- គេហទំព័រ https://www.nec.gov.kh/khmer/category/392 ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២
- គេហទំព័រ https://www.nec.gov.kh/khmer/content/6186 ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២
- គេហទំព័រ https://www.nec.gov.kh/khmer/content/5665 ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២
- គេហទំព័រ https://realsaminn.blogspot.com/2017/03/blog-post_20.html?m=1 ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧
- គេហទំព័រ https://www.nec.gov.kh/khmer/content/3921 ថ្ងៃទី០៦ ខែឧសភាឆ្នាំ២០១៩
- គេហទំព័រ https://www.nec.gov.kh/khmer/content/3266 ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធគតិយុត្តិ

# ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# ព្រះរាជក្រម

នស/រកម/០៣១៥/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល លេខ........ ថ្ងៃទី........ ឆ្នាំ២០១... ម៉ោង........ បញ្ជូនទៅ........

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៣/០០១/២០១៥ កបធ.ច ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# គណៈកម្មាធិការជាតិ
# រៀបចំការបោះឆ្នោត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

**មាត្រា ២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានឈ្មោះជាអក្សរកាត់ "គ.ជ.ប" ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីអនុវត្តការងាររបស់ខ្លួន ។

**មាត្រា ៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីជានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ។

សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិក នៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត ។

## ជំពូកទី ២
## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### ផ្នែកទី ១
### ការរៀបចំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ០៩ (ប្រាំបួន) រូប ដែលរួមមាន ៖

- ប្រធាន ០១ (មួយ) រូប

**មាត្រា ៥.-**

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរទាំងពីរភេទ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ក្នុងពេលបំពេញការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-មានអាយុយ៉ាងតិច ៣៥ (សាមសិបប្រាំ) ឆ្នាំ គិតដល់ថ្ងៃតែងតាំង

-មានសិទ្ធិបោះឆ្នោត

-មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ

-មានបទពិសោធន៍ការងារយ៉ាងតិច ១០ (ដប់) ឆ្នាំ

-មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ។

**មាត្រា ៦.-**

សមាសភាពទាំង ០៩ (ប្រាំបួន) រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសដោយ ៖

-០៤ (បួន) រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល

-០៤ (បួន) រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង

-០១ (មួយ) រូបទៀត ជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវធ្វើការសម្របសម្រួលជាមួយគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីប្រកាសជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសាធារណៈ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ ។ បន្ទាប់មក គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវសម្របសម្រួលជាមួយគណបក្សទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បី

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

ពិនិត្យជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពីក្នុងចំណោមបេក្ខជន ដែលបានដាក់ពាក្យស្នើសុំ ដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

បែបបទ និងនីតិវិធីនៃការជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ផ្អែកលើសមាសភាពដែលបានជ្រើសរើសខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវរៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីរដ្ឋសភាថ្មីចូលកាន់តំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

## មាត្រា ៧.-

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអាណត្តិ ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលសមាសភាពថ្មីចូលកាន់តំណែង ។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ច ដើម្បីចាត់ចែងរៀបចំបោះឆ្នោតស្របតាមច្បាប់ជាធរមាន ។

## មាត្រា ៨.-

មុខងារជាប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្ដោះអាសន្ន រហូតដល់ថ្ងៃបញ្ចប់មុខតំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយ ត្រូវសុំលាលែងពីគណបក្សនយោបាយ ហើយអាចចូលជាសមាជិកគណបក្សនយោបាយវិញបាន ក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ឆ្នាំ បន្ទាប់ពីបញ្ចប់អាណត្តិការងារ ឬបាត់បង់មុខតំណែង ឬត្រូវបានបណ្តេញចេញ ដូចមានចែងក្នុងមាត្រា ៧ មាត្រា ៩ និងមាត្រា ១០ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិក ឬ/និងជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងមន្ត្រីរាជការ ត្រូវសុំលាលែងពីអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ ។

## មាត្រា ៩.-

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោមៈ

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

## មាត្រា ១០.-

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានគណនេយ្យភាពចំពោះមុខរដ្ឋសភា ។

ការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសមត្ថកិច្ចរបស់រដ្ឋសភា ។

## មាត្រា ១១.-

ក្នុងករណីដែលមានប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់ពីមុខតំណែង គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវសម្របសម្រួលជាមួយគណបក្សនយោបាយពាក់ព័ន្ធ ដើម្បីប្រកាសជ្រើសរើសជាសាធារណៈនូវបេក្ខភាពបេក្ខជនដែលត្រូវជំនួសមុខតំណែងដែលទំនេរ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ ។

បន្ទាប់មក គណបក្សពាក់ព័ន្ធត្រូវជ្រើសរើសសមាសភាពថ្មីពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ដាក់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំដាក់សមាសភាពថ្មីនេះ ជូនរដ្ឋសភាបោះឆ្នោតទុកចិត្ត តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ ក្នុងករណី ដែលគ្មានការរៀបចំបោះឆ្នោត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ករណីគណបក្សនយោបាយពាក់ព័ន្ធខកខានមិនបានជ្រើសរើសសមាសភាពថ្មីតាមការកំណត់ខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវធ្វើការជ្រើសរើសបេក្ខភាពបេក្ខជន ដែលត្រូវជំនួសមុខតំណែងទំនេរនោះ ដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាពក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ថ្ងៃ ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ថ្ងៃ ក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។

បែបបទ នីតិវិធីនៃការដាក់ពាក្យ ការជ្រើសរើស និងការរៀបចំបញ្ជីបេក្ខជនដាក់ជូនរដ្ឋសភា ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានទទួលការតែងតាំងជំនួសកន្លែងទំនេរនោះ ត្រូវធ្វើសច្ចាប្រណិធានចូលកាន់តំណែងភ្លាម ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរនោះ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១២.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើឧបនាយករដ្ឋមន្ត្រី ។

អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើទេសរដ្ឋមន្ត្រី ។

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើរដ្ឋមន្ត្រី ។

**មាត្រា ១៣.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយមិនលម្អៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ការបំភិតបំភ័យ ឬការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីបុគ្គល ឬស្ថាប័នណាមួយឡើយ ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបានការធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ក្នុងករណីចាំបាច់ តាមសំណូមពររបស់សាមីខ្លួន ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនត្រូវទទួលខុស

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៤
## ការរៀបចំគណៈកម្មការការិយាល័យបោះឆ្នោត

**មាត្រា ៣៤.-**

គណៈកម្មការការិយាល័យបោះឆ្នោតនីមួយៗ មានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| -ប្រធាន | ០១ (មួយ) រូប |
| -អនុប្រធាន | ០១ (មួយ) រូប |
| -លេខាធិការ | ០១ (មួយ) រូប |
| -សមាជិក | ០៣ (បី) រូប ។ |

**មាត្រា ៣៥.-**

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែង តែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

**មាត្រា ៣៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងគណៈកម្មការមួយ ដើម្បីធ្វើការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ។

បែបបទ និងនីតិវិធីជាក់ស្តែងនៃដំណើរការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣៧.-**

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដោយផ្អែកលើលទ្ធផលនៃការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោតរបស់គណៈកម្មការជ្រើសរើស ដូចមានចែងក្នុងមាត្រា ៣៦ នៃច្បាប់នេះ ។

**មាត្រា ៣៨.-**

ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព

# ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

# ព្រះរាជក្រម

នស/រកម/០៣១៥/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៨/០០២/២០១៥ កបធ.ច ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការបោះឆ្នោតជ្រើសតាំង
# តំណាងរាស្ត្រ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្រុមចុះឈ្មោះបោះឆ្នោតនូវសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារច្បាប់ដើម ដែលមានចុះនាមត្រកូល នាមខ្លួន ភេទ សញ្ជាតិ និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ប្រជាពលរដ្ឋនោះ ក្នុងសៀវភៅនោះ ។

ក្នុងករណីដែលប្រជាពលរដ្ឋមិនទាន់មានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារប្រជាពលរដ្ឋនោះ អាចស្នើសុំលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំសង្កាត់ ដែលសាមីខ្លួនមានលំនៅឋាន ឬទីសំណាក់ ។ អាជ្ញាធរឃុំ សង្កាត់ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅនេះជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលានៃការចុះឈ្មោះបោះឆ្នោត ស្របតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តកំណត់ ។

ឃ.ក្នុងករណីដែលប្រជាពលរដ្ឋមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវ ដូចមានចែងក្នុងចំណុច ខ និងចំណុច គ នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោតត្រូវ ៖

-ចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីឈ្មោះបោះឆ្នោត

-កត់ឈ្មោះប្រជាពលរដ្ឋនោះ ចូលក្នុងសៀវភៅបញ្ជីបោះឆ្នោត

-ចេញបង្កាន់ដៃបញ្ជាក់អំពីការចុះឈ្មោះជូនសាមីខ្លួន

-បញ្ជាក់ប្រាប់ប្រជាពលរដ្ឋ អំពីការិយាល័យបោះឆ្នោតដែលប្រជាពលរដ្ឋនោះ ត្រូវទៅបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋណាដែលមានឈ្មោះក្នុងសៀវភៅបញ្ជីបោះឆ្នោតរួចហើយ ក្រុមចុះឈ្មោះបោះឆ្នោត គ្រាន់តែពិនិត្យភស្តុតាងនៃការចុះឈ្មោះរបស់ជននោះ ប្រសិនបើជននោះមិនស្ថិតក្នុងករណីណាមួយដូចបានចែងក្នុងកថាខណ្ឌទី ៣ នៃចំណុច ក នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោត ត្រូវធ្វើបច្ចុប្បន្នភាពឈ្មោះរបស់ជននោះ ចូលក្នុងបញ្ជីបោះឆ្នោត ។

**មាត្រា ៥២.-**

ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហាមឃាត់មិនឲ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ព្រមទាំងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងសាលាឃុំ សង្កាត់ ឬទីកន្លែងកំណត់ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។

ក្នុងករណី មានជនណាបង្កការអុកឡុកវឹកវរ ក្រុមចុះឈ្មោះបោះឆ្នោត ត្រូវស្នើសុំអន្តរាគមន៍ជាបន្ទាន់ពីអាជ្ញាធរមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យនានា ។

**មាត្រា ៥៣.-**

ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្នុងករណីមានភស្តុតាងបញ្ជាក់ថាជនណាដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមមាត្រា ៤៦ និងចំណុច ក ចំណុច ខ និងចំណុច គ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោតត្រូវបដិសេធការចុះឈ្មោះបោះឆ្នោតរបស់ជននោះ ដោយត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធ ០១ (មួយ) ច្បាប់ ជូនសាមីខ្លួន ។

-ផ្តល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា៥៤នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធ ០១ (មួយ) ច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

**មាត្រា ៥៤.–**

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួនត្រូវបានបដិសេធដោយក្រុមចុះឈ្មោះបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

**មាត្រា ៥៥.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ានេះ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

**មាត្រា ៥៦.–**

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោត អនុវត្តការចុះឈ្មោះតាមលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ ពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធ ០១ (មួយ) ច្បាប់ជូនសាមីខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ហើយអាចអនុញ្ញាតឲ្យបោះឆ្នោត គឺជាជនដែលស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

**មាត្រា ៩៤.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោត ហើយត្រូវបិទផ្សាយបញ្ជីទាំងនេះនៅគ្រប់ការិយាល័យបោះឆ្នោត ៣០ (សាមសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៩៥.–**

គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត អាចសុំសេចក្តីចម្លងនៃបញ្ជីឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនេះ ដោយបង់ថ្លៃ ។ តម្លៃគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

**មាត្រា ៩៦.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់ជូនការិយាល័យបោះឆ្នោតនីមួយៗនូវសម្ភារដូចតទៅ តាមចំនួនសមស្រប ០១ (មួយ) ថ្ងៃមុន ថ្ងៃបោះឆ្នោត ៖

១- បញ្ជីបោះឆ្នោត ។
២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។
៣- ហិបឆ្នោត ។
៤- បន្ទប់សម្ងាត់ ។
៥- ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត ។
៦- ទឹកជ្រលក់សម្រាប់សម្គាល់ថាបានបោះឆ្នោតហើយ ។
៧- សោ និងប្រដាប់ឃ្លុំ ។
៨- ក្រដាសបែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។
៩- ប៊ិចសរសេរដែលមានគុណភាពល្អ ។
១០- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។
១១- ចង់ប្លាស្ទិក ។
១២- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត ។



# ឧបសម្ព័ន្ធទី៣៖ ច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## និង

## ច្បាប់ស្តីពីវិសោធនកម្មច្បាប់

## ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

នស / រកម / ០៣០១ / ០៤

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តមធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និងពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤២/០០៤/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

នស/រកម/០៦០៦/០២០

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់យល់ស្របលើទម្រង់និងគតិច្បាប់ ព្រមទាំងលើខ្លឹមសារ នៃអត្ថបទច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែ កាលពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ២ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ០៧៨/០០៦/២០០៦ កបធ.ច ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ច្បាប់នេះត្រូវអនុវត្តចំពោះឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

***មាត្រា ៣.- ថ្មី***

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល៤(បួន)ខែយ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ ។

**មាត្រា ៤.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

**មាត្រា ៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល ÷

- បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ
- មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តែមួយប៉ុណ្ណោះ ។

**មាត្រា ៦.-**

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗដូចដែលបានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យក្នុងរយៈពេលយ៉ាងតិច ៩ខែ មុនថ្ងៃបោះឆ្នោត ។

## ជំពូកទី ២
## ការគ្រប់គ្រងការបោះឆ្នោត
## ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

***មាត្រា ៧.- ថ្មី***

ការចាត់ចែងរៀបចំនិងគ្រប់គ្រងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានបង្កើតឡើងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតែងតាំងគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ។

***មាត្រា ៨.- ថ្មី***

សមាជិកនិងមន្ត្រីគ្រប់រូបនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវប្រកាន់ជំហរឯករាជ មិនលម្អៀង និងស្មោះត្រង់ក្នុងការអនុវត្តអំណាច មុខងារ ភារកិច្ចរបស់ខ្លួន ។